Two weeks ago I attended the Third World Buddhist Conference at the *Veang* and Chaktomuk Theater. High monks and dignitaries from sixteen countries were there. At the opening ceremony our own King Sihanouk gave a speech, and then with the queen stood on the steps of the Silver Pagoda to have his photo taken with the delegates. I saw him—but only from two hundred meters away. The king was surrounded by officials, invited guests, and security guards. Most days I am not near the king at all. The closest I get is to hear about him on the radio or see his picture in the newspaper. I saw the king two years ago on Independence Day, but at the Conference was the first time I had ever heard him speak. So on December 5, 2002, for me the King of Cambodia had come close ... but not very close.

How close has the King of Heaven come? If kings of this earth rarely come near, but usually surround themselves with guards and dignitaries and finery, surely the God of Creation will keep himself at greater distance from us still. But Christmas is the story of how God came very, very close.

The one whose title is Immanuel—God with us—was born as a baby. But he was not born in a palace to a royal family, so that only a privileged few could ever hope to see him. He was born to a poor, traveling couple that found themselves with no place to sleep for the night. They were temporarily homeless; there was no place even for his mother Mary to give birth. So apparently she did so in some kind of feeding room for animals. It may have been a barn of some type, or a cave, or a place outside where animals are fed. But after Jesus was born his mother laid him in an animals' feeding box. If this baby, Jesus, is truly Immanuel, then God has indeed come very close.

The baby's first visitors were not prime ministers or court dignitaries, but shepherds. Shepherds were common figures in Israel in those days. They performed an important role in that society, because sheep provided both wool for clothing and meat for food and religious sacrifices. But shepherds were not generally wealthy people. It would be today as if the angels announced the baby's birth to motodups or cyclo drivers. These are people who are familiar to us, they perform an important role in our society, but they are not generally wealthy or influential people. Not people we would expect to be the first to be informed that a king has been born—that God has come close to us in human form. But it is a symbol of just how close God came that first Christmas that Jesus was born to a shelterless, traveling couple, and that his first visitors were not the wealthy politician or merchants, but shepherds. God has come so close that he is available to *everybody*.

The fact that Jesus was totally human—so like us in every way—caused many people in his day to doubt that he was Immanuel. In John 1 we hear Nathaniel grumbling, "Can anything good come out of Nazareth?" In John 7 the people of Jerusalem debate among themselves, "Have the authorities really concluded that he is the Messiah? But we know where this man is from; when the Messiah comes, no one will know where he is from." In Mark 6 and Matthew 13 we hear people ask, "Where did this man get this wisdom and these miraculous powers? Isn't this the carpenter's son? Isn't his mother's name Mary, and aren't his brothers James, Joseph, Simon, and Judas? Aren't all his sisters with us? Where then did this man get all these things?" And so they took offense at him and refused to believe that

he was God With Us, because God had come so close as to seem indistinguishable at first glance. The book of Isaiah says, "He had no beauty or majesty to attract us to him, nothing in his appearance that we should desire him." Only when we look closer and hear his wisdom and watch his deeds and observe his sinlessness do we recognize that the scriptures that had predicted Immanuel have been fulfilled in this man.

The New Testament goes on to describe how close God has come to us in Jesus. The Apostle John begins his first letter by saying, "That which was from the beginning, which we have heard, which we have seen with our eyes, which we have looked at and our hands have touched—this we proclaim...." He begins his gospel by telling us that "The Word became flesh and made his dwelling among us. We have seen his glory, the glory of the One and Only, who came from the Father, full of grace and truth.... No one has ever seen God, but God the One and Only, who is at the Father's side, has made him known." When Thomas doubted that Jesus had been raised from the dead Jesus appeared to him and urged him to put his finger where the nails had been in Jesus' hands, and to thrust his hand into where the spear had pierced Jesus' side. That's very, very close. In fact, the book of Hebrews says that God's Son "had to be made like [us] in every way, in order that he might become a merciful and faithful high priest ... and ... make atonement for the sins of the people." As a result "we do not have a high priest who is unable to sympathize with our weaknesses, but we have one who has been tempted in every way, just as we are—yet was without sin." At Christmas we celebrate the birth of one whose title is Immanuel—God with us. The Great and Powerful God of Creation has indeed come very, very close.

All of this is Good News for us. All of this means we don't need to fear or seek help from all kinds of spirits and other forces—real or imagined. The Great God himself cares for us, and he is powerful to save. Jesus taught that God loves us so much that even the hairs on our heads are numbered. He told his disciples that "the Father [that is, God] himself loves you because you have loved me and have believed that I came from God." Therefore "my Father will give you whatever you ask in my name." Jesus promised that if anyone loved him he

would obey his teaching and "My Father will love him, and we will come to him and make our home with him." Our bondage to the spirits is broken because the Great God loves us and lives in us as Christians, and he is greater than any other power. Christmas is Good News—the Great God has come close and lives with all who accept the pardon purchased by his Son.

Have you accepted God's love to you in Jesus yet? Have you said, "All my life I have been serving shadows and spirits—either things that I have imagined but that aren't really there, or things that are evil and should not be served. But now I turn from them to the Great God who has come close and shown me who he is in Jesus"? Have you understood what Christmas is—not a fat man with a white beard in a red suit who gives presents, not a decorated tree and special songs, but the birthday of the man in whom God has come close?

This Christmas message that God has come close to us in the person of Jesus not only has something to say to people who are not Christians, but also to those of us who are. How do we Christians think of Christmas, and how do we celebrate it?

We are gathered today in a large stadium with many people in attendance. We have banners and music and dancing and a powerful sound system. We have invited dignitaries and special guests, and many of us are wearing our nice clothing. It is good for us to celebrate Christ's birth in this way, and show how important it is to us. It is good for us to meet together in a large meeting as Christians from different churches and denominations to show how our common faith in Jesus and love for him unites us, and is more important than the denominational differences that we sometimes allow to divide us. It is good to worship and be glad together like this in a big way.

But is that the only way we can celebrate Christmas? Is a big meeting the only way we can show how important it is to us that the Son of God has come among us to be our savior?

Let us remember that Christmas commemorates the coming of Immanuel—"God With Us." Let us remember that when God came to us in Christ he came close—not as presidents and kings and prime ministers do today, surrounded by guards to keep common people away, and dressed in fine clothing. He came close—born to a shelterless

couple, wrapped in strips of cloth, and laid in a box from which animals eat their food. His first visitors were shepherds. He looked so much like ordinary people and grew up in such an unimportant village that many could not believe he was anything special. John says he came so close that his eyes looked upon him and his hands touched him. Christmas is not primarily about big meetings and expensive programs, although, as I said, these are good and certainly have their place. Christmas is first of all God coming close to everyday people in the everyday concerns of their daily life.

So, as Christians, if we want our non-Christian neighbors to know this Jesus whom we love, we need to be little "Immanuels" to them. Jesus said to his apostles, "As the Father has sent me, so send I you." He sends us the same way God sent him—to live among people and show them by our lives what God is like. To care for them where we can in their everyday needs and problems.

So when a Christian takes a meal to a young mother dying of AIDS, that is Christmas for that woman. That is someone coming close to her in her poverty, and ministering to her in God's name. When a church gets together and decides to clean up its neighborhood streets, or teach local street children how to read, or donate rice to a family that lost their whole crop to a flood, that is showing what Christmas is. God coming close to us where we are, where we can see what he is like and experience his practical love and care. Our celebrations like this one can be very encouraging to us and honoring to God. But if that is all we do then our non-Christian neighbors are likely to say, "The Christians are celebrating one of their religious festivals again. That has nothing to do with me; I have my own religion and festivals." On the other hand, if we serve them up close, where they are, in practical and meaningful ways, then they will understand that Christmas is the coming of Immanuel—"God With Us"—right to where we live and work and play and struggle. Perhaps in time they will feel encouraged to abandon their fear of lesser spirits, because they will realize that the Great God himself has come close.

សំណុំនិក្ខរ ៤/២ (កក្កដា ២០០៣): ៣៤-៤៨



# ព្រះជាម្ចាស់យាងមកក្បែរជីវិតនិងរូបរាងអ្នកហើយ

*បណ្ឌិត រ៉ាស់សែល បាវផើស*

នៅក្នុងទីក្រុងអានុរ៉ាតបាពូរ៉ា ដែលស្ថិតនៅក្នុងភាគខាងជើងនៃប្រទេសស៊ីរីលង្កា មានកោះមួយលាតសន្ធឹងបង្ហាញរាងយ៉ាងស្រស់ត្រកាល ដែលនៅលើនោះមានទីសក្ការៈបូជាដ៏ពិសិដ្ឋបំផុត ។ ដើមពោធិមួយដើម ដុះនៅទីនោះដែលមានមនុស្សជំណាលតគ្នាថា នៅក្រោមដើមពោធិ៍នោះហើយដែលព្រះពុទ្ធបានត្រាស់ដឹងជាព្រះ ។ គេបានធ្វើរបងដែកព័ទ្ធជុំវិញដើមឈើដ៏ចំណាស់ និងពិសិដ្ឋនោះ និងមានពួកអ្នកធ្វើធម្មយាត្រារាប់រយនាក់មកកាន់កន្លែងនោះជារៀងរាល់ថ្ងៃដើម្បីមកតាំងភាវនានៅមុខដើមឈើនោះ ។ នៅពេលថ្មីនេះពេលដែលខ្ញុំបានទៅទស្សនាកន្លែងនោះ ខ្ញុំបានឃើញមនុស្សជាច្រើនអង្គុយបិទភ្នែក លើកដៃសំពះទៅដើមឈើនោះ ។ ខ្ញុំបានសួរទៅអ្នកនាំផ្លូវរបស់ខ្ញុំថា "តើពួកគេកំពុងសំពះបួងសួង

---

*អត្ថបទនេះបានអធិប្បាយជាលើកដំបូងនៅក្នុងពិធីបុណ្យណូអែលនៅក្នុងទីក្រុងភ្នំពេញ ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០០២ ។*

ទៅព្រះពុទ្ធឬ?" នាងបានឆ្លើយថា "ទេ" ។ "ព្រះពុទ្ធបានយាងផុតពីជីវិតនេះទៅហើយ គឺព្រះអង្គយាងចូលនិព្វាន ។ ព្រះអង្គទ្រង់មិនបានព្រះសណ្ដាប់ឮ ឬក៏អាចឆ្លើយតាមពាក្យបួងសួងនោះបានឡើយ ។ មនុស្សទាំងអស់នេះកំពុងតែតាំងភាវនាសញ្ជឹងគិតចំពោះធម៌របស់ព្រះពុទ្ធដែលទ្រង់សំដែង និងកំពុងបង្ហាញការគោរពដល់ធម៌ទាំងនោះ។ បើគេត្រូវការអ្វីមួយ និងចង់បួងសួងនោះ គេត្រូវបួងសួងទៅដល់ទេវតា" ។

មានរឿងដូចគ្នានេះដែរ កើតមានឡើងនៅកន្លែងផ្សេងទៀតនៅក្នុងលោកយើងនេះ និងចំពោះសាសនាដទៃទៀតក្រៅពីព្រះពុទ្ធសាសនា ។ មានមនុស្សជាច្រើនដឹងជាក់នៅក្នុងចិត្តថា មានព្រះអាទិករ ដែលជាអ្នករៀបចំតាក់តែងបង្កើតនូវរបស់សព្វសារពើដែលយើងអាចមើលឃើញ ។ ពិភពលោកនេះមានការរចនារៀបចំយ៉ាងល្អ និងជីវិតដែលកំពើករស់នៅលើផែនដីទៀតសោត ក៏មានលក្ខណៈចំរុះផងដែរ ។ និយាយឲ្យងាយស្ដាប់ទៅ របស់ទាំងអស់កើតឡើងដោយសារឱកាសចៃដន្យណាមួយ ឬបានមកពីដំណើរច្រំដែលវិលចុះវិលឡើងគ្មានទីបញ្ចប់របស់ប្រវត្តិសាស្ត្រ ។ បើខ្ញុំប្រទះឃើញកំព្យូទ័រមួយគ្រឿង ខ្ញុំដឹងថាប្រាកដជាមានរណាម្នាក់ជាអ្នកគ្រោង និងបង្កើតតាមគំរោងដែលគេគ្រោងយ៉ាងល្អិតល្អន់ជាមិនខាន នាឡិការអាចកើតឡើងបានលុះត្រាតែមានជាងជាអ្នកបង្កើតវាឡើង ម៉ូតូត្រូវតែកើតចេញពីអ្នកដែលផលិតម៉ូតូ ។ ដូចគ្នាដែរ គ្រាប់ពូជស្រូវដែលអាចចាក់ឬសដើម្បីបឺតយកជាតិទឹកនោះ និងដើម្បីឲ្យអាចលាស់ស្លឹកទទួលយកពន្លឺថ្ងៃ និងខ្យល់ សត្វស្លាបដែលស្រែកយំកញ្ជ្រៀវនៅលើអាកាសព្រមទាំងមនុស្សដែលអាចគិត និងច្នៃធ្វើរបស់សព្វសារពើទាំងអស់នោះ ក៏មានអ្នកគ្រោងបង្កើត និងអ្នកបង្កើតដ៏ឈ្លាសវៃលៃលកច្នៃឲ្យកើតមកដែរ ។ យើងកើតមកនេះ មិនមែនដោយចៃដន្យនោះឡើយ ហើយក៏មានមនុស្សជាច្រើនទទួលស្គាល់ការនោះដែរ ។ ប៉ុន្តែមនុស្សជាច្រើនដែលដឹងថា មានព្រះអាទិករបង្កើតគេមក នោះខ្លាចថាព្រះអង្គគង់នៅឆ្ងាយពីគេណាស់ប្រហែលជាព្រះអង្គមិន

បានយកព្រះទ័យទុកដាក់និងយើងឡើយ ហើយយើងក៏មិនអាចស្គាល់ព្រះអង្គបានដែរ ។ យើងជាស្នាព្រះហស្តព្រះអង្គទៅវិញទេ ដែលមិនស្គាល់ព្រះអង្គ ។ ដូច្នេះ បើសិនជាយើងត្រូវការជំនួយនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើងនោះ យើងត្រូវខិតចូលទៅកៀកកិតនឹងព្រះអង្គដោយមាននូវភាពជិតស្និទ្ធខាងឯវិញ្ញាណ ។

មនុស្សយើងខ្លះមានការភ័យខ្លាចខ្មោច ឬវិញ្ញាណដូនតាដែលបានចែកស្ថានទៅហើយ ដោយខ្លាចវិញ្ញាណទាំងនោះមកធ្វើបាបដល់គេ អ្នកខ្លះទៀតនោះក៏ខំសែនព្រេនដល់អ្នកតា ជនជាតិថៃគេសែនព្រេនដល់វិញ្ញាណ ដែលហៅថា "ភី"[១] នៅក្នុងប្រទេសភូមាគេយកផ្លែដូង និងក្រណាត់ក្រហមសែនដល់វិញ្ញាណឈ្មោះថា "ណាត់" ។ ពួកអ្នកដែលកាន់សាសនាឥស្លាមវិញ គេមិនខ្វល់ក្នុងការសែនព្រេនដល់វិញ្ញាណដែលហៅថា "ចីន" នោះឡើយ ។ បើរៀបរាប់ទៅឃើញថា មានច្រើនថែមទៀត ។ អារម្មណ៍ជារួមរបស់មនុស្សទាំងអស់នៅលើសកលលោកយើងនេះ គឺផ្តោតលើព្រះដែលសំខាន់បំផុត និងមានអំណាចបំផុតគឺជាព្រះដ៏ធំឧត្តមដែលបានបង្កើតយើង ដោយហេតុនោះបានជាយើងគិតថាព្រះអង្គនោះធំណាស់ ឬនៅឆ្ងាយពីយើងណាស់ ឬព្រះអង្គលែងខ្វល់ និងថែទាំមនុស្សដែលព្រះអង្គបង្កើតមកហើយ ទើបបានជាយើងខំស្វែងរកជំនួយពីកន្លែងផ្សេងៗ ដែលគ្មានអំណាចដូចជាព្រះអង្គវិញ ។

យើងប្រទះឃើញហេតុការណ៍បែបនេះនៅក្នុងព្រះគម្ពីរដែរ ។ កំលោះវ័យក្មេងជនជាតិអ៊ីស្រាអែលម្នាក់ឈ្មោះ ដានីយ៉ែល ។ គាត់បានថ្វាយបង្គំដល់ព្រះដ៏ពិត និងជាព្រះដ៏ធំឧត្តម ប៉ុន្តែប្រទេសជាតិត្រូវទទួលបរាជ័យនៅក្នុងសង្គ្រាមដោយចាញ់ពួកខ្មាំងសត្រូវរបស់ខ្លួន គឺពួកបាប៊ីឡូន ។ ហេតុដូច្នេះ គេបានបង្ខំដានីយ៉ែលឲ្យទៅបំរើដល់ស្តេចសាសន៍ដទៃនៅក្នុងក្រុងបាប៊ីឡូន ។ នៅពេល

---

[១] *ភី ជាពាក្យថៃ ដែលមានន័យជាភាសាខ្មែរថា ខ្មោច*

យប់មួយនោះ ស្តេចទ្រង់ផ្ទំលង់លក់ទៅ ក៏យល់សប្តិ ហើយស្តេចចង់ដឹងពីអត្ថន័យនៃការយល់សប្តិនោះ ។ ព្រះអង្គក៏បានកោះហៅពួកអ្នកប្រាជ្ញនោះមកដោយមានបន្ទូលថា "ចូរប្រាប់អញមកមើល តើអញយល់សប្តិអំពីអ្វី ហើយសូមប្រាប់មកអញមើល តើកាត់ស្រាយយ៉ាងម៉េច?" ។ បណ្តាពួកអ្នកប្រាជ្ញបានឆ្លើយថា "ឱព្រះករុណាថ្លៃវិសេស សូមព្រះអង្គមានបន្ទូលប្រាប់មកយើងចុះ នោះយើងនឹងកាត់ស្រាយទូលដល់ព្រះអង្គក្រាបទូល" ។ ស្តេចឆ្លើយថា "ទេ! សូមប្រាប់មកអញ ថាអញយល់សប្តិពីអ្វី ។ ពេលនោះអញនឹងដឹងថា ឯងរាល់គ្នាមិនប្រឌិតរឿងនៅក្នុងគំនិតរបស់ឯង តែសូមប្រាប់ពីការកាត់ស្រាយសប្តិដ៏ត្រឹមត្រូវប្រាប់ដល់អញ" ។ ពួកអ្នកប្រាជ្ញនិយាយទាំងស្រងាកចិត្ត ទូលទៅស្តេចថា "គ្មានមនុស្សណាម្នាក់នៅលើផែនដីនេះ អាចធ្វើបាននូវអ្វីដែលព្រះអង្គចង់បាននោះឡើយ! ទោះបីជាមានអ្នកខ្លាំងពូកែយ៉ាងណា ក៏គ្មាននរណាធ្លាប់សួរនូវរឿងចម្លែក បែបនេះបានដែរ ទោះអ្នកនោះជាអ្នកប្រើមន្តអាគម ឬគ្រូអាបធ្មប់ ឬអ្នកសិក្សាពីផ្កាយមើលជោគជតារាសីក៏ដោយ ។ អ្វីដែលព្រះករុណាមានបន្ទូលនោះ គឺពិបាកជ្រុលពេកហើយ ។ គ្មាននរណាម្នាក់អាចកាត់ស្រាយថ្វាយព្រះអង្គបានឡើយ លើកលែងតែព្រះប៉ុណ្ណោះ ហើយអ្នកដែលអាចធ្វើការនោះ មិនបានរស់នៅក្នុងចំណោមយើងទេ" ។ តើយើងបានឮនូវអ្វីដែលពួកអ្នកប្រាជ្ញទាំងអស់នោះបាននិយាយឬទេ? មានព្រះដែលឈ្លាសវៃ និងមានអំណាចចេស្តា និងសូម្បីតែរឿងរ៉ាវបែបដូចជាអ្វីដែលមនុស្សបានយល់សប្តិនោះដែរ ។ ប៉ុន្តែព្រះទាំងអស់នោះនៅឆ្ងាយពីយើង ហើយក៏មិនមែនរស់នៅជាមួយយើង ឬក៏អាចនិយាយមកកាន់យើងទៀតផង យើងគ្មានផ្លូវណាដែលអាចឲ្យយើងទាក់ទងជាមួយព្រះទាំងនោះបានឡើយ ។ នៅពេលដែលយើងមានបញ្ហា យើងត្រូវស្វែងរកជំនួយពីកន្លែងដែលមិនសូវមានអំណាចចេស្តាប៉ុន្មាន (ជួនកាលវិញ្ញាណនោះដែលយើងចង់ឲ្យជួយនោះ ជាវិញ្ញាណក្លែងក្លាយទៀតផង) ។

ដូច្នេះ នេះជាផ្នត់គំនិតដែលចាក់ស្រេះជាប់នៅក្នុងប្រវត្តិសាស្ត្រ ដែលជឿថាមានព្រះដ៏ធំឧត្តម (ឬយ៉ាងហោចណាស់ក៏ជឿថាមានព្រះដែរ) ។ តែការដែលជឿនោះគឺថា ព្រះអង្គធំពេក ឬនៅឆ្ងាយពេក ។ យើងមិនអាចទាក់ទងព្រះអង្គបានឡើយ ព្រះអង្គក៏មិនអាចជួយយើង ឬព្រះអង្គនឹងមិនជួយយើងឡើយ ។

ការដែលយើងឃ្លាតឆ្ងាយពីព្រះដែលឈ្លាសវៃ និងមានបុទ្ធិចេស្តាដែលជួយនោះ គឺអាចជាការមួយគួរឲ្យយើងភ័យខ្លាចទៅវិញទេ ។ ខ្ញុំបានអាននូវរឿងរ៉ាវនៃជីវិតជាច្រើននៅក្នុងស្រុកខ្មែរក្រោមរបប ខ្មែរក្រហម ហើយខ្ញុំទើបចាប់ផ្តើមអានរឿងមួយផ្សេងទៀត ។ នៅក្នុងរឿងនោះ អ្នកនិពន្ធជាក្មេងស្រីអាយុប្រាំបួនឆ្នាំដែលជួបនូវភព្វវាសនាអាក្រក់គឺបានឆ្លងកាត់ថ្ងៃ ១៧ មេសា ឆ្នាំ១៩៧៥ នៅពេលដែលពួកទាហាន ប៉ុល ពត ជម្លាសអ្នកទីក្រុងភ្នំពេញឲ្យទៅរស់នៅតាមខេត្ត ។ នៅពេលដែលក្មេងស្រីនេះ និងគ្រួសាររបស់នាងរត់កាត់ហ្វូងមនុស្សដែលពពាក់ពពូនរត់លួនគេចចេញពីការប្រយុទ្ធគ្នារបស់ពួកខ្មែរក្រហម ខណៈពេលដែលចេញពីទីក្រុង គ្រួសារនាងបានប្រទះឃើញក្មេងប្រុសអាយុ បីឆ្នាំ ម្នាក់កំពុងវង្វេងបាត់ឪពុកម្តាយ ឈរយំស្រែករកឪពុកម្តាយរបស់គេ ។ ក្មេងប្រុសនោះកំពុងវង្វេងបាត់ឪពុកម្តាយ ឈរតែម្នាក់ឯងក្នុងពិភពថ្មីចម្លែកពោរពេញដោយគ្រោះថ្នាក់ និងគួរឲ្យភ័យខ្លាចបំផុត ។ ឪពុកម្តាយដែលជាទីអាងមាំមួន ធ្លាប់តែមានភាពកក់ក្តៅឲ្យគាត់នោះ និងការពារគាត់បានបាត់ស្រមោលសូន្យឈឹងទាំងអស់ ។

យើងទាំងអស់គ្នា ពេលខ្លះមានអារម្មណ៍ដូចជាក្មេងនោះអ៊ីចឹងដែរ ។ យើងយល់ថា យើងកំពុងនៅតែឯង ត្រូវពឹងផ្អែកលើប្រាជ្ញាផ្ទាល់ខ្លួនដែលមានព្រំដែនកំណត់ (ហើយពេលខ្លះក៏មិនត្រឹមត្រូវទៀត) យើងនឹងត្រូវពឹងលើធនធានទាំងឡាយនៅក្នុងលោកដែលយើងកំពុងជួបប្រទះនូវការរាំងស្ងួត និងទុរ្ភិក្ស និងសង្គ្រាម អំពើពុករលួយ ភេរវកម្ម ជម្ងឺអេដស៍ និងកុមារមានជម្ងឺ ។ យើងស្រែកអំពាវនាវតែគ្មានអ្នកណាជួយយើងសោះ ។ ព្រះដ៏ធំឧត្តម បើសិនជាមានមែន ព្រះអង្គនៅឆ្ងាយ និងស្ងាត់ឈឹងទៅទៀត ។ ដូច្នេះ យើងត្រូវតែស្រវាអ្វី

ក៏ដោយដែលនៅជិតដៃ ដែលយើងគិតថាអាចជួយយើងបាន មិនខុសគ្នានិងមនុស្សលង់ទឹកឡើយ ដែលស្រវារកអ្វីក៏ដោយឲ្យតែនៅជិតដៃ ដើម្បីជួយឲ្យគាត់អាចបណ្តែតខ្លួនបាន ។

មានការពិតខ្លះៗដែរ ដែលថាព្រះដ៏ធំឧត្តមគង់នៅឆ្ងាយពីយើង ។ ពីមុននោះមិនដូច្នេះឡើយ តែឥឡូវនេះពិតដូច្នេះមែន ។ នៅពេលដែលព្រះបង្កើតមនុស្សប្រុស និងមនុស្សស្រីដំបូង ព្រះធ្លាប់យាង និងជជែកជាមួយពួកគេ ។ ប៉ុន្តែនៅថ្ងៃមួយ គេបានបះបោរទាស់ទទឹងទៅនឹងបទបញ្ញត្តិរបស់ព្រះអង្គ ដោយហេតុនោះហើយ ទើបគេត្រូវបាត់បង់នូវសម្ព័ន្ធភាពជិតស្និទ្ធជាមួយនឹងព្រះដ៏ធំឧត្តមប្រកបដោយបុទ្ធានុភាពអស្ចារ្យនោះទៅ ។ ជាច្រើនសតវត្សក្រោយមក ព្រះជាម្ចាស់មានបន្ទូលទៅកាន់ប្រជារាស្ត្ររបស់ទ្រង់ គឺប្រជារាស្ត្រអ៊ីស្រាអែលថា "ពិតប្រាកដមែន ព្រោះព្រះពាហុនៃព្រះយេហូវ៉ា មិនមែនរួញខ្លីក្នុងការសង្គ្រោះនោះឡើយ ព្រះកាណ៌របស់ព្រះអង្គក៏មិនធ្ងន់ដែលស្តាប់មិនឮនោះដែរ ។ ប៉ុន្តែដោយព្រោះអំពើរំលងរបស់អ្នករាល់គ្នា បានលាក់ព្រះភ័ក្ត្រព្រះជាម្ចាស់ពីឯងរាល់គ្នា ដោយហេតុនេះហើយ ទើបព្រះអង្គមិនអាចស្តាប់ឯងឮ" ។ គឺប្រៀបដូចជាលោកអ្នក និងខ្ញុំមិនបានពាក់ស្បែកជើងចូលទៅក្នុងផ្ទះ ដោយព្រោះថាយើងដើរកាត់ភក់ល្បាប់ទឹកស្អុយនៅតាមផ្លូវនោះ យើងត្រូវដោះស្បែកជើងនោះដាក់នៅខាងក្រៅផ្ទះ ចំណែកឯព្រះជាម្ចាស់វិញ ទ្រង់ជាព្រះបរិសុទ្ធស្អាត នោះព្រះអង្គក៏មិនអនុញ្ញាតឲ្យមានអំពើកំណាច និងការបះបោរណាមួយមកនៅចំពោះព្រះវត្តមានរបស់ព្រះអង្គបានឡើយ ។ អំពើបាបរបស់យើងបានញែកយើងចេញពីព្រះរបស់យើង អំពើបាបនោះឯងដែលបាំងព្រះភ័ក្ត្ររបស់ព្រះអង្គ ទើបព្រះអង្គទ្រង់ព្រះសណ្តាប់យើងមិនឮ ។ យើងទាំងអស់គ្នាប្រៀបដូចជាកូនក្មេងអាយុបីឆ្នាំដែលស្រែកដង្ហោយហៅរកឪពុកម្តាយ តែគ្មានរណាស្តាប់ឮសោះ ហើយកូននោះឯងកំពុងស្ថិតនៅក្នុងពិភពលោកមួយដែលកំពុងច្របូកច្របល់ ។

ប្រសិនបើនេះជាព្រះរាជសារតែមួយគត់ដែលព្រះគម្ពីរបានបង្រៀននោះ តាមពិតទៅជារឿងមួយគួរឲ្យសោកស្តាយមែនទែន ។ ប៉ុន្តែមានការមួយដែលកើតឡើង គឺព្រះរាជកំណើតរបស់ព្រះយេស៊ូ ។ ថ្ងៃនោះ គឺជារឿងរ៉ាវស្តីពីព្រះដ៏ធំឧត្តម គឺជាព្រះដែលបានបង្កើតយើងមក ព្រះអង្គស្គាល់យើង និងព្រះអង្គជាព្រះឈ្លាសវៃ និងមានចេស្តាគ្រប់គ្រាន់ដើម្បីជួយយើង ព្រះអង្គនោះឯងយាងមកជិតយើង ។ តាមពិតទៅព្រះអង្គអាក់អន់ស្រពន់ព្រះទ័យដោយព្រោះអំពើបាបរបស់យើងលើសជាងការដែលយើងពាក់ស្បែកជើងកខ្វក់ទៅទៀត តែដោយសារសេចក្តីស្រឡាញ់របស់ព្រះអង្គនោះឯងទើបព្រះអង្គយាងមកជិតយើង ។ ព្រះអង្គបានយាងមកជិតដើម្បីបង្ហាញឲ្យយើងស្គាល់ថា ព្រះអង្គជាអង្គដែលអាចសំអាតយើងពីគ្រប់អំពើបាប និងដើម្បីជួយផ្សះផ្សាយើងឲ្យមានភាពជិតស្និទ្ធដូចដែលយើងធ្លាប់មានពីមុនមកជាមួយព្រះជាម្ចាស់ ។ ព្រះគម្ពីរសញ្ញាចាស់បានទស្សន៍ទាយពីអ្នកដែលមកជួយរំដោះដែលមានព្រះនាមថា "អេម៉ាញូអែល" ។ "អេម៉ាញូអែល" គឺជាភាសាហេព្រើរ ដែលមានពាក្យបីម៉ាត់តូចៗរួមជាមួយគ្នាមានន័យថា "ព្រះគង់នៅជាមួយយើង" ។ នៅក្នុងគម្ពីរសញ្ញាថ្មីបានប្រាប់ពីដំណើររឿងនៃព្រះដែលមានព្រះនាមថា អេម៉ាញូអែល មានន័យថា ព្រះជាម្ចាស់គង់នៅជាមួយយើងនេះ ត្រូវយាងមកដោយរបៀបណា? មកក្នុងមធ្យោបាយណាទៅ និងតើជិតស្និទ្ធយ៉ាងណាទៅ ដែលព្រះអាទិករបង្កើតរបស់សព្វសារពើយាងមករកយើង?

អស់រយៈពេលពីរសប្តាហ៍ ដែលខ្ញុំបានចូលរួមសន្និបាតផ្នែកព្រះពុទ្ធសាសនានៅក្នុងព្រះបរមរាជវាំង និងនៅសាលចតុមុខ ។ សម្តេចសង្ឃ និងមន្ត្រីសង្ឃជាន់ខ្ពស់ពីបណ្តាប្រទេសទាំង១៦បានមកចូលរួមនៅទីនោះ ។ ក្នុងពេលចាប់ផ្តើមពិធីនោះ ព្រះមហាក្សត្ររបស់យើង ព្រះបាទ នរោត្តម សីហនុ បានថ្លែងសន្ទរកថា ហើយបន្ទាប់មក សម្តេចព្រះ អគ្គមហេសី និងទ្រង់គង់នៅលើកាំជណ្តើរនៃវត្តប្រាសាទខេមរិនដើម្បីគង់ប្រថាប់រួមជាមួយ នឹងគណៈប្រតិភូ ។

ខ្ញុំបានឃើញព្រះអង្គផ្ទាល់ភ្នែក ប៉ុន្តែនៅចំងាយប្រហែលជាពីររយម៉ែត្រ ។ ព្រះមហាក្សត្រមានមន្ត្រីជាន់ខ្ពស់ជាច្រើន នៅឈរអម ។ អ្នកទាំងនោះជាភ្ញៀវដែលគេបានអញ្ជើញមកឲ្យចូលរួម និងជាកងរក្សាព្រះអង្គ ។ ភាគច្រើនបំផុតនោះគឺខ្ញុំមិនដែលបាននៅជិតព្រះមហាក្សត្រសោះ ។ អ្វីដែលជិតបំផុតដែលខ្ញុំបានទទួលនោះគឺ ខ្ញុំបានឮសំឡេងរបស់ព្រះអង្គតាមវិទ្យុ ឬបានឃើញព្រះឆាយាល័ក្ខណ៍របស់ព្រះអង្គតាមសារពត៌មាន ។ កាលពី២ឆ្នាំកន្លងទៅ ខ្ញុំបានឃើញព្រះមហាក្សត្រនៅថ្ងៃបុណ្យ ឯករាជ្យ ប៉ុន្តែនៅថ្ងៃសន្និបាតនេះ គឺជាគ្រាដំបូងដែលខ្ញុំបានឃើញច្បាស់ និងបានឮទ្រង់មានបន្ទូល ។ ដូច្នេះ នៅថ្ងៃទី ៥ ខែធ្នូ ឆ្នាំ២០០២ កន្លងទៅនេះ ខ្ញុំគិតថាខ្ញុំបាននៅជិតព្រះមហាក្សត្រនៃប្រទេសកម្ពុជាបានមកកៀកកិត... ប៉ុន្តែ មិនបាននៅកៀកកិតនឹងព្រះអង្គឡើយ ។

តើព្រះមហាក្សត្រនៃស្ថានសួគ៌យាងមកជិតប៉ុណ្ណាទៅ? បើសិនជាស្តេចនៅលើផែនដីទាំងអស់នោះកម្រមកជិតយើង ហើយពេញទៅដោយមនុស្សថ្នាក់កំពូលៗចាំហែរហមអមដំណើរ ព្រមទាំងការពារមិនឲ្យយើងចូលទៅជិតបានទៅហើយ ចុះទំរាំព្រះជាម្ចាស់ដែលជាព្រះអាទិករង្កើតលោកទាំងមូល ពិតប្រាកដណាស់ទ្រង់ក៏នៅឆ្ងាយពីយើងលើសពីនេះទៅទៀតដែរ? ប៉ុន្តែដោយសារតែបុណ្យព្រះរាជកំណើតរបស់ព្រះអង្គ ដំណើររឿងនោះបានបង្ហាញពីរបៀបដែលព្រះជាម្ចាស់បានយាងមកជិតយើងគឺជិតបំផុត ។

ព្រះអង្គដែលមានព្រះនាមថា "អេម៉ាញូអែល" ដែលស្រាយថា ព្រះអង្គគង់ជាមួយយើងគឺបានប្រសូត្រមកជាទារកហើយ ។ តែព្រះអង្គមិនបានប្រសូត្រនៅក្នុងព្រះរាជវាំង ឬជារាជបុត្ររបស់វង្សានុវង្សរបស់អង្គក្សត្រាណាមួយនោះឡើយ បើសិនជាព្រះអង្គប្រសូត្រនៅក្នុងរាជវាំង នោះមានមនុស្សតែមួយចំនួនតូចតែប៉ុណ្ណោះ ដែលមានឯកសិទ្ធិសង្ឃឹមថាអាចចូលទៅគាល់ព្រះអង្គបាន ។ ព្រះអង្គបានប្រសូត្រមកក្នុងគ្រួសារក្រីក្រមួយដែលកំពុងតែធ្វើដំណើរ ហើយរកកន្លែងស្នាក់នៅក៏គ្មានផង ។ សូម្បីតែរកកន្លែងសំរាប់មាតារបស់ព្រះអង្គសម្រាល

ព្រះអង្គក៏គ្មានដែរ ។ ដូច្នេះ មាតារបស់ព្រះអង្គត្រូវសម្រាលព្រះអង្គនៅក្នុងក្រោលសត្វ ។ គឺអាចជាកន្លែងក្រោលម៉្យាង ឬក៏ជានៅក្នុងល្អាងអ្វីមួយ ឬក៏អាចជានៅកន្លែងខាងក្រៅ ដែលជាកន្លែងដាក់ចំណីសត្វ ។ ប៉ុន្តែបន្ទាប់ពីព្រះយេស៊ូបានប្រសូត្ររួចមក មាតាព្រះអង្គបានផ្តេកទ្រង់នៅក្នុងស្នូកសត្វ ។ បើសិនជាព្រះឱរសយេស៊ូនេះ ពិតជាអេម៉ាញូអែលមែន អ៊ីចឹងព្រះជាម្ចាស់ពិតជាយាងមកជិតយើងមែនហើយ ។

អ្នកដែលបានមកសួរសុខទុក្ខព្រះឱរសមុនគេបង្អស់នោះ មិនមែនជានាយករដ្ឋមន្ត្រី ឬជាមន្ត្រីជាន់ខ្ពស់ផ្នែកតុលាការឡើយ តែជាពួកអ្នកគង្វាល ។ ពួកអ្នកគង្វាលជាស្រទាប់វណ្ណៈដ៏សាមញ្ញបំផុតនៅក្នុងប្រទេសអ៊ីស្រាអែលសម័យនោះ ។ គេមានតួនាទីសំខាន់នៅក្នុងសង្គម ពីព្រោះចៀមផ្តល់រោមសំរាប់ធ្វើសំលៀកបំពាក់ និងសាច់សំរាប់ជាអាហារ និងសំរាប់ធ្វើយញ្ញបូជាផ្នែកសាសនា ។ ប៉ុន្តែពួកគង្វាលជាទូទៅ មិនមែនជាមនុស្សមានសម្បត្តិស្តុកស្តម្ភនោះឡើយ ។ បើប្រៀបនឹងសម័យសព្វថ្ងៃនេះវិញ ទេវតាអាចនឹងប្រកាសប្រាប់ពីដំណឹងនៃបុត្រតូចនោះទៅដល់ពួកអ្នករត់ម៉ូតូឌុប និងអ្នកធាក់ស៊ីក្លូ ។ ទាំងនេះគឺជាមនុស្សដែលមានឋានៈស្រដៀងនឹងយើងដែរ ដែលគេមានតួនាទីសំខាន់នៅក្នុងសង្គមរបស់យើង តែជាទូទៅគេមិនមានទ្រព្យសម្បត្តិស្តុកស្តម្ភ ឬក៏មិនមែនជាមនុស្សមានអំណាចប៉ុន្មានដែរ ក្នុងន័យនេះ បានន័យថាព្រះជាម្ចាស់យាងមករកយើងដោយយកនិស្ស័យជាមនុស្ស ។ ប៉ុន្តែការនេះគឺជានិមិត្តសញ្ញាដែលបង្ហាញពីរបៀបដែលព្រះជាម្ចាស់យាងមកជិតយើងនៅថ្ងៃកំណើតរបស់ព្រះអង្គលើកដំបូង ព្រះអង្គបានកើតនៅក្នុងគ្រួសារដែលគ្មានទីជំរក គឺកើតចំពេលគ្រួសារនេះកំពុងធ្វើដំណើរ ហើយភ្ញៀវដំបូងគេដែលមកសួរសុខទុក្ខនោះ មិនមែនជាអ្នកនយោបាយ អ្នកជំនួញដែលមានសម្បត្តិស្តុកស្តម្ភ ប៉ុន្តែជាអ្នកគង្វាល ។ ព្រះអង្គយាងមកជិតប្រយោជន៍ឲ្យមនុស្សគ្រប់រូបអាចចូលទៅគាល់ព្រះអង្គបានគ្រប់គ្នា។

ហេតុការណ៍មួយដែលថា ព្រះយេស៊ូជាមនុស្សសុទ្ធសាធដូចជាយើងរាល់គ្នាបេះបិទនោះ បានធ្វើឲ្យមនុស្សជាច្រើននៅក្នុងសម័យនោះសង្ស័យភាពអេម៉ាញូអែលរបស់ព្រះអង្គ ។ នៅក្នុងយ៉ូហានជំពូក១ យើងឮ ណាថាណែលរអ៊ូថា "តើអាចមានអ្វីល្អទេដែលចេញមកពីណាសារ៉ែត?" នៅក្នុងយ៉ូហាន ជំពូក៦ ពួកអ្នកស្រុកក្រុងយេរូសាឡិម បានពិភាក្សាវែកញែកដោះស្រាយក្នុងចំណោមពួកគេថា "តើពួកអាជ្ញាធរពិតជាសន្និដ្ឋានថា អ្នកនោះជាព្រះមែស៊ីមែនឬ? តែយើងដឹងថា បុរសនោះមកពីណា ពេលដែលព្រះមែស៊ីយាងមកនោះគ្មាននរណាម្នាក់ដឹងថា ព្រះអង្គយាងមកពីណាឡើយ" ។ នៅក្នុងម៉ាកុស ជំពូក៦ និងម៉ាថាយ១៣ យើងបានឮមនុស្សសួរគ្នាថា "មនុស្សនេះបានទទួលប្រាជ្ញាមកពីណា និងអំណាចចេស្ដាអាចធ្វើការអស្ចារ្យទាំងនេះបានមកពីណា? តើអ្នកនេះមិនមែនជាកូនជាងឈើទេឬអី? និងគាត់មិនមានប្អូនប្រុសឈ្មោះយ៉ាកុប យ៉ូសែប ស៊ីម៉ូន និងយូដាសទេឬអី? តើមិនមែនទេឬអី ដែលប្អូនស្រីៗរបស់គាត់នៅជាមួយយើងនោះ? អ៊ីចឹង តើបុរសម្នាក់នេះបានរឿងទាំងនេះមកពីណា?" ។ ដោយហេតុដូច្នេះហើយ បានជាគេមិនសូវសប្បាយចិត្តនឹងព្រះអង្គព្រមទាំងមិនជឿថា ព្រះអង្គជាព្រះដែលគង់នៅជាមួយយើង ពីព្រោះថាព្រះជាម្ចាស់បានមកជិតយើងពេក នៅពេលដែលយើងមើលទៅហាក់បីដូចជាពិបាកបែងចែកឲ្យបានដឹងច្បាស់ តើមែន ឬមិនមែននោះ ។ កណ្ឌគម្ពីរអេសាយបានចែងថា "ព្រះអង្គមិនមានអ្វីដែលល្អ ឬបារមីដែលអាចទាក់ទាញយើងទៅចំពោះទ្រង់នោះទេ គឺទ្រង់គ្មានរូបអង្គខាងក្រៅអ្វីសោះដែលទាក់ទាញធ្វើឲ្យយើងប្រាថ្នាចង់បានព្រះអង្គ" ។ គឺនៅពេលដែលយើងសំម្លឹងទៅជិតព្រះអង្គទៅៗ ហើយឮពីប្រាជ្ញាញាណរបស់ព្រះអង្គ និងសំលឹងទៅលើការប្រព្រឹត្តិរបស់ទ្រង់ ហើយសង្កេតទៅលើភាពគ្មានបាបសោះរបស់ព្រះអង្គនោះ ទើបយើងទទួលស្គាល់ថាព្រះបន្ទូលដែលបានទាយទុកមកអំពី អេម៉ាញូអែល គឺត្រូវបានសំរេចនៅក្នុងអង្គមួយនេះឯង ។

គម្ពីរសញ្ញាថ្មីពិពណ៌នាបន្តអំពីកៀកកិតយ៉ាងណាទៅ ដែលព្រះទ្រង់យាងមកជិតពួកគេតាមរយៈអង្គព្រះយេស៊ូ ។ លោកសាវ័ក យ៉ូហាន ចាប់ផ្តើមសៀវភៅដំបូងរបស់គាត់ដោយនិយាយថា "ឯសេចក្តីដែលមានតាំងពីដើមមក ដែលយើងខ្ញុំបានឮ ហើយភ្នែកបានឃើញ ក៏បានមើល ហើយដៃបានប៉ះពាល់ ខាងឯព្រះបន្ទូលជីវិត..." គាត់បានផ្តើមនៅក្នុងគម្ពីរដំណឹងល្អដោយប្រាប់យើងថា "ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា យើងរាល់គ្នាបានឃើញសិរីល្អទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រាតែមួយដែលមកពីព្រះវរបិតា មានពេញជាព្រះគុណ និងសេចក្តីពិត... គ្មានអ្នកណាដែលឃើញព្រះឡើយ មានតែព្រះរាជបុត្រាតែមួយដែលគង់នៅក្នុងឱរាព្រះវរបិតាប៉ុណ្ណោះ ទ្រង់បានសំដែងឲ្យស្គាល់ព្រះអង្គ" ។ ពេលដែលថូម៉ាសមានការសង្ស័យអំពីការដែលព្រះយេស៊ូរស់ពីសុគតឡើងវិញ ព្រះយេស៊ូបានលេចឲ្យគាត់ឃើញ ហើយជំរុញគាត់ឲ្យដាក់ម្រាមដៃមកចំលើស្នាមដែកគោលដែលទ្រង់ត្រូវគេបោះភ្ជាប់នៅលើឈើឆ្កាងលើព្រះហស្តរបស់ព្រះអង្គ និងទៅលើចំណុចដែលគេបានចាក់ព្រះអង្គ ។ គឺទ្រង់យាងមកកៀកជិតនឹងយើងខ្លាំងណាស់ ។ តាមពិតទៅក្នុងកណ្ឌហេព្រើរនិយាយថា ព្រះរាជបុត្រានៃព្រះ "ហេតុនោះ បានជាគួរឲ្យទ្រង់ដូចជាបងប្អូនទ្រង់គ្រប់ជំពូកដែរ ដើម្បីឲ្យបានធ្វើជាសម្តេចសង្ឃដែលមានព្រះទ័យមេត្តាករុណា ហើយក៏ស្មោះត្រង់ក្នុងការទាំងប៉ុន្មានខាងឯព្រះប្រយោជន៍នឹងថ្វាយដង្វាយឲ្យធួននឹងបាបរបស់ប្រជាជនទាំងឡាយ" ដូច្នេះលទ្ធផល "ដ្បិតសម្តេចសង្ឃនៃយើង ទ្រង់មិនមែនមិនអាចនឹងអាណិតអាសូរដល់សេចក្តីកំសោយរបស់យើងរាល់គ្នានោះទេ ព្រោះទ្រង់បានត្រូវសេចក្តីល្បួងគ្រប់យ៉ាងដូចជាយើងរាល់គ្នាដែរ តែឥតធ្វើបាបឡើយ" ។ នៅឯបុណ្យណូអែលយើងប្រារព្ធពិធីបុណ្យខួបកំណើតអង្គដែលមាននាមថា អេម៉ាញូអែល ដែលមានន័យថា ព្រះគង់ជាមួយយើង ។ ព្រះដែលជាអាទិករដ៏អស្ចារ្យ និងមានគ្រប់ព្រះចេស្តាពិតប្រាកដណាស់បានយាងមកកៀកជិតនឹងយើងខ្លាំងណាស់ ។

ទាំងអស់នេះសុទ្ធតែជាដំណឹងល្អសំរាប់យើង ។ ទាំងអស់នេះគឺមានន័យដល់យើងថា យើងមិនត្រូវមានការភ័យខ្លាច ឬស្វែងរកជំនួយពីវិញ្ញាណ ឬអានុភាពណាផ្សេងៗទៀតឡើយ ទោះបីជាពិត ឬតាមការស្រមើស្រមៃក្តី ។ ព្រះដ៏អស្ចារ្យអង្គនេះផ្ទាល់យកព្រះទ័យទុកដាក់ចំពោះយើង ហើយទ្រង់មានអំណាចក្នុងការជួយសង្គ្រោះ ។ ព្រះយេស៊ូបានបង្រៀនថា ព្រះស្រឡាញ់មនុស្សខ្លាំងដល់ម៉្លេះ សូម្បីតែសក់មួយសរសៃដែលធ្លាក់ពីលើក្បាលយើងក៏ទ្រង់ជ្រាបដែរ ។ ទ្រង់បានប្រាប់ដល់សិស្សព្រះអង្គថា "ព្រះវរបិតា (ដែលជាព្រះ) ព្រះអង្គផ្ទាល់ស្រឡាញ់អ្នករាល់គ្នា ដោយព្រោះអ្នករាល់គ្នាបានស្រឡាញ់ខ្ញុំ ហើយ បានជឿថាខ្ញុំបានមកអំពីអំពីព្រះអង្គនោះឯង" ។ ដូច្នេះ "ព្រះវរបិតាខ្ញុំ នឹងប្រទានឲ្យអ្នករាល់គ្នាតាមអ្វីដែលអ្នករាល់គ្នាសូមដោយនូវឈ្មោះខ្ញុំ" ។ ព្រះយេស៊ូបាន សន្យាថា បើអស់អ្នកណាស្រឡាញ់ព្រះអង្គ ដោយធ្វើតាមសេចក្តីបង្រៀនរបស់ព្រះអង្គនោះ "ព្រះវរបិតារបស់ទ្រង់នឹងស្រឡាញ់ពួកគេ ហើយទ្រង់នឹងយាងទៅចំពោះពួកគេ ហើយនឹងសំណាក់នៅជាមួយពួកគេដែរ" ។ ចំណងដែលយើងមានចំពោះវិញ្ញាណទាំងអស់នោះនឹងត្រូវកាត់ផ្តាច់ ពីព្រោះតែព្រះដ៏ធំអស្ចារ្យស្រឡាញ់យើង ហើយគង់នៅជាមួយយើងដែលជាគ្រីស្ទបរិស័ទ ហើយទ្រង់មានអំណាចលើសជាងវិញ្ញាណណាៗទាំងអស់ ។ បុណ្យណូអែលជាដំណឹងល្អ ព្រះដ៏ធំអស្ចារ្យបានយាងមកកៀកនឹងយើងហើយ ព្រមទាំងគង់ជាមួយអស់អ្នកណាដែលទទួលការអត់ទោសតាមរយៈព្រះរាជបុត្រារបស់ព្រះអង្គ ។

តើអ្នកបានទទួលសេចក្តីស្រឡាញ់របស់ព្រះតាមរយៈព្រះយេស៊ូហើយឬនៅ? តើអ្នកបាននិយាយថា "មួយជីវិតរបស់ខ្ញុំបំរើតែស្រមោល និងវិញ្ញាណដែលជារបស់ដែលខ្ញុំបានស្រមើស្រមៃ ប៉ុន្តែវាមិនពិតជានៅទីនោះឡើយ ឬជាវិញ្ញាណអាក្រក់ដែលខ្ញុំមិនគួរបំរើឡើយ ។ តែឥឡូវនេះ ខ្ញុំបានងាកចេញពីវាអស់ហើយ ដោយបែមករកព្រះដ៏ធំអស្ចារ្យដែលបានយាងមកកៀកនឹងខ្ញុំវិញដែលបង្ហាញខ្ញុំឲ្យឃើញតើទ្រង់ជាអង្គណានៅក្នុងអង្គព្រះយេស៊ូ?" តើអ្នកមានការ

យល់ដឹងច្បាស់ទេថា អ្វីទៅដែលជាគ្រីស្ទបរិស័ទ មិនមែនជាមនុស្សធាត់ដែលមានពុកមាត់ស ពាក់អាវពណ៌ក្រហម ដែលតែងតែឲ្យអំណោយនោះទេ ហើយក៏មិនមែនដើមណូអែល ដែលតែងតែតាក់តែងជាមួយភ្លើងចិញ្ចាចចិញ្ចែង និងចំរៀងពិសេសផ្សេងៗនោះដែរ ប៉ុន្តែគឺកំណើតរបស់មនុស្សម្នាក់ដែលជាព្រះ ហើយតាមអង្គនោះឯងដែលព្រះយាងមកកៀកជិតនឹងយើង ។

ដំណឹងបុណ្យណូអែល អំពីព្រះយាងមកកៀកនឹងយើងនៅក្នុងអង្គព្រះយេស៊ូ មិនមែនជាដំណឹងសំរាប់តែអស់អ្នកដែលមិនមែនជាគ្រីស្ទបរិស័ទនោះឡើយ ប៉ុន្តែដល់យើងដែលជាគ្រីស្ទបរិស័ទដែរ តើយើងដែលជាគ្រីស្ទបរិស័ទគិតយ៉ាងម៉េចដែរអំពីបុណ្យណូអែល តើយើងអបអរយ៉ាងដូចម្តេចដែរ?

យើងបានជួបគ្នាថ្ងៃនេះនៅក្នុងស្តាតដ៏ធំមួយ ជាមួយមនុស្សយ៉ាងច្រើនដែលបានចូលរួម ។ យើងមានបដា តន្ត្រី របាំ និងប្រព័ន្ធសំឡេងយ៉ាងប្រណិតជាទីបំផុត ។ យើងបានអញ្ជើញភ្ញៀវកិត្តិយស និងភ្ញៀវពិសេសផ្សេងៗ ព្រមទាំងយើងទាំងអស់គ្នាស្លៀកពាក់សំលៀកបំពាក់យ៉ាងសមរម្យ ។ វាជាការល្អណាស់សំរាប់យើងក្នុងអបអរសាទរខួបកំណើតព្រះគ្រីស្ទក្នុងមធ្យោបាយនេះ ដោយបង្ហាញថា វាមានសារៈសំខាន់សំរាប់យើងខ្លាំងណាស់ ។ វាជាការល្អដែលយើងជួបជុំគ្នានៅក្នុងការជួបជុំយ៉ាងធំសំបើមនេះក្នុងនាមជាគ្រីស្ទបរិស័ទដែលមកពីក្រុមជំនុំ និងនិកាយផ្សេងៗ ដែលបង្ហាញឲ្យឃើញពីជំនឿរួមនៅក្នុងព្រះយេស៊ូ និងដោយសេចក្តីស្រឡាញ់របស់ទ្រង់ យើងអាចរួបរួមគ្នា ហើយការរួបរួមគ្នានេះឯងមានសារៈសំខាន់ជាងនិកាយខុសគ្នា ដែលពេលខ្លះបំបែកយើងចេញពីគ្នា ។ វាជាការល្អដែលយើងអាចថ្វាយបង្គំ និងរីករាយជាមួយគ្នាយ៉ាងដូច្នេះបាន ។

តើនេះគឺជាមធ្យោបាយតែមួយឬ ដែលយើងអាចអបអរបុណ្យណូអែលបាន? តើមានតែការប្រជុំជាធំឬ ដែលជាមធ្យោបាយតែមួយគត់

បង្ហាញឲ្យឃើញថា មានសារៈសំខាន់ចំពោះយើងដែលព្រះរាជបុត្រានៃព្រះបាន យាងមកនៅក្នុងចំណោមយើង ដើម្បីជាព្រះអង្គសង្គ្រោះនៃយើង?

សូមឲ្យយើងចងចាំថា បុណ្យណូអែល គឺជាការរំលឹកពីការយាងមក របស់អេម៉ាញូអែល "ព្រះគង់ជាមួយយើង" ។ សូមឲ្យយើងចងចាំដែរថា ព្រះយាងមកយើងតាមរយៈអង្គព្រះគ្រីស្ទ ទ្រង់បានយាងមកកៀកជិតនឹងយើង មិនមែនដូចជាប្រធានាធិបតី មហាក្សត្រ ឬនាយករដ្ឋមន្ត្រី ដូចសព្វថ្ងៃ នេះឡើយ ដែលហ៊ុំព័ទ្ធដោយអ្នកការពារ ដើម្បីរក្សាមនុស្សសាមញ្ញឲ្យនៅឆ្ងាយ ហើយអស់ លោកទាំងនោះមានសំលៀកបំពាក់យ៉ាងថ្លៃៗ ។ ទ្រង់បានយាងមកកៀក មក ប្រសូត្រជាមួយគ្រួសារដែលគ្មានទីជំរក រុំដោយក្រណាត់រហែក ហើយផ្ដុំនៅ ក្នុងស្នូកដែលសំរាប់ដាក់ចំណីសត្វ ។ អ្នកមកសួរព្រះអង្គដំបូងគឺជាអ្នកគង្វាល ចៀម ។ ទ្រង់មើលទៅហាក់បីដូចជាមនុស្សសាមញ្ញបំផុត ហើយចំរើនវ័យឡើង នៅក្នុងភូមិតូចមួយដែលមនុស្សជាច្រើនមិនអាច ជឿបានថាទ្រង់មានអ្វីពិសេស នោះឡើយ ។ លោកយ៉ូហាននិយាយថា ទ្រង់យាងមកកៀកខ្លាំងណាស់ រហូត ដល់ភ្នែកគាត់បានឃើញនិងដៃគាត់បានប៉ះព្រះអង្គ ។ គ្រីស្ទបរិស័ទមិនមែនស្ថិត នៅការប្រជុំធំៗ និងកម្មវិធីថ្លៃៗនោះទេ ទោះបីខ្ញុំបាននិយាយរួចមកហើយថា វាជាល្អ និងមានកន្លែងវាក៏ដោយ ។ ប៉ុន្តែបុណ្យណូអែល គឺជាការដែលទ្រង់ យាងមកកៀកជិតនឹងមនុស្សសាមញ្ញរាល់ថ្ងៃ និងការរស់នៅរាល់ថ្ងៃក្នុងជីវិតគេ ម្នាក់ៗ ។

ដូច្នេះក្នុងនាមយើងជាគ្រីស្ទបរិស័ទ ប្រសិនបើចង់ឲ្យអ្នកជិតខាង យើងដែលមិនមែនជាគ្រីស្ទបរិស័ទ ស្គាល់ព្រះគ្រីស្ទដែលយើងស្រឡាញ់នេះ យើងត្រូវតែជា "អេម៉ាញូអែល" តូចដល់ពួកគេ ។ ព្រះយេស៊ូមានបន្ទូលដល់ សិស្សរបស់ព្រះអង្គថា "ដូចជាព្រះវរបិតាបញ្ជូនខ្ញុំ ខ្ញុំក៏បញ្ជូនអ្នករាល់គ្នាឲ្យ ទៅដែរ" ។ ទ្រង់បញ្ជូនយើង ដូចជាព្រះវរបិតាបញ្ជូនទ្រង់អ៊ីចឹងដែរ ដើម្បីទៅ រស់នៅក្នុងចំណោមមនុស្ស ហើយបង្ហាញពួកគេអំពីជីវិតរបស់យើងឲ្យស្គាល់

ព្រះអង្គ ថាមានលក្ខណៈយ៉ាងដូចម្ដេច ។ ដើម្បីឲ្យយើងអាចយកចិត្តទុកដាក់ចំពោះពួកគេបាន គឺតាមរយៈសេចក្ដីត្រូវការ និងបញ្ហាប្រចាំថ្ងៃរបស់ពួកគេ ។

ដូច្នេះនៅពេលដែលគ្រីស្ទបរិស័ទម្នាក់ យកអាហារទៅឲ្យម្ដាយដ៏ក្មេងម្នាក់កំពុងរង់ចាំសេចក្ដីស្លាប់ដោយជម្ងឺអេដស៍ នោះហើយគឺជាបុណ្យណូអែលសំរាប់ស្ត្រីនោះ ។ គឺមានម្នាក់ដែលចូលទៅកៀកនឹងភាពក្រីក្ររបស់គាត់ និងចែកចាយដល់នាងនូវព្រះនាមនៃព្រះ ។ នៅពេលដែលក្រុមជំនុំជួបជុំគ្នា ហើយសំរេចចិត្តលាងសំអាតផ្លូវរបស់អ្នកជិតខាងខ្លួន ឬបង្រៀនក្មេងៗអនាថាក្នុងស្រុកនៅតាមផ្លូវឲ្យចេះអានអក្សរ ឬផ្ដល់អំណោយជាអង្ករដល់គ្រួសារដែលខូចផលស្រូវតាមរយៈទឹកជំនន់នោះហើយ ជាអត្ថន័យនៃបុណ្យណូអែលនោះ ។ ព្រះបានយាងមកកៀកនឹងយើងហើយ ទោះជាយើង នៅកន្លែងណាក៏ដោយ យើងអាចឃើញថា ទ្រង់ជានរណា ហើយទទួលនូវបទពិសោធន៍នៃសេចក្ដីស្រឡាញ់ និងការយកព្រះទ័យទុកដាក់របស់ព្រះអង្គ ។ ការដែលយើងអបអរសាទររបៀបនេះ ផ្ដល់ឲ្យយើងនូវការលើកទឹកចិត្តយ៉ាងខ្លាំង ហើយលើកតំកើងព្រះទៀតផង ។ ប៉ុន្ដែ បើមិនយ៉ាងដូច្នេះទេ អ្នកជិតខាងរបស់យើងដែលមិនមែនជាគ្រីស្ទបរិស័ទគេនឹងនិយាយថា "គ្រីស្ទបរិស័ទគេប្រារព្ធពិធីបុណ្យសាសនារបស់ពួកគេម្ដងទៀតហើយ" ។ ការដែលពួកគេធ្វើនោះ មិនទាក់ទងអ្វីនឹងខ្ញុំទេ ខ្ញុំក៏មានសាសនា និងពិធីបុណ្យផ្ទាល់របស់ខ្ញុំដែរ" ។ ផ្ទុយទៅវិញ ប្រសិនបើយើងបំរើកៀកនឹងគេ នៅកន្លែងរបស់គេក្នុងផ្លូវពិត និងមានអត្ថន័យនោះ គេនឹងមានការយល់ដឹងថា បុណ្យណូអែល គឺជាការយាងមករបស់អេម៉ាញូអែល "ព្រះគង់ជាមួយយើង" នៅចំកន្លែងដែលយើងរស់នៅធ្វើការលេង និងបញ្ហា ។ ប្រហែលជាពេលមួយ ពួកគេនឹងមានអារម្មណ៍លើកទឹកចិត្តដោយលះបង់ការភ័យខ្លាចនៃវិញ្ញាណតូចៗដែលពួកគេមាន ដោយព្រោះតែពួកគេទទួលស្គាល់ថា ព្រះដ៏ធំអស្ចារ្យបានយាងមកដោយផ្ទាល់កៀកជិតនឹងគេហើយ ។

HONEYCOMB 4/2 (July 2003): 49–55



# A Christian Perspective on Corruption

*Arun SOK NHEP*

Corruption is widely practiced in Cambodia. Even some highly respected professionals, such as schoolteachers, medical doctors, and lawyers, are infected by this disease. Corruption has become so common that even Christians—nationals and expatriates alike—often find themselves unconsciously involved in it (let alone a few "believers" who actively practice corruption as part of their strategy to expand the "Kingdom of God").

Since God has called us to live in this society, we should reflect on this problem from his perspective, rather than ignore or overlook it.

## The Universality of Corruption

Corruption is a universal social phenomenon with which every society has struggled throughout human history. Each culture has its own definition for corruption, but all consider it to be immoral.

Some define corruption as using a public position for personal benefit. For others it is a means to divert someone from his duty. The former focuses on the action of taking bribes; the latter on offering them. But both actions are fraudulent.

The problem of corruption dates back to the beginning of recorded human history. In the Old Testament, when Samuel spoke to the Israelites after having chosen a king for them, he asked, "From whose hand have I accepted a bribe to make me shut my eyes?"[1] Samuel's question shows that the practice was already known in ancient Israel. Later, when King Jehoshaphat appointed judges for the people of Judah, he urged them to "Judge carefully, for with Yahweh our God there is no injustice or partiality or bribery."[2]

Throughout history, corruption has begun with electoral and political delinquency. Candidates purchase votes with money. Civil servants pay bribes to access higher positions that entitle them to more money and honor. The practice was well known in ancient Roman society. The Romans enacted laws to punish or banish people practicing corruption. In ancient Greece, corruption was often related to judicial affairs. One paid jurists to hand down verdicts that flew in the face of evidence, or paid public officials for improper favors.

Many countries nowadays have laws against fraud in elections, or in political, administrative, and judicial affairs. In modern society, corrupt practices may also take place within the economic system, such as financial manipulation or business corruption. Economic corruption is sometimes practiced at the international level. Business people pay bribes to obtain contracts or markets so that they can make larger profits. They sometimes increase their profits by using inferior materials and cheating on the quality of work provided.

Some governments often fight corruption because it deprives them of finances. Others oppose it because corruption leads to inefficiency (a citizen's needs are met only if he pays for the official's attention).

Corporations fight corruption because it reduces profits. The legal profession opposes bribery because it violates the principle of free and equal justice for all, not just those who can pay for it.

---

[1] 1 Sam 12:3.

[2] 2 Chron 19:7.

Institutions such as Christian churches perceive corruption as an ethical problem. They therefore denounce this practice, as they do other forms of sin.

## Riches, Poverty and Corruption

In many societies, corruption is practiced at all levels, from simple day-to-day transactions to high-level state decisions. In such societies, the triad of "riches, poverty, and corruption" are so intertwined that we cannot approach these phenomena separately. Corruption becomes so deeply engrained that it comprises part of "the system"—the way things get done. Parents bribe schoolteachers to give their children good grades, or allow them to graduate. Medical care is accessible only to those who can bribe the practitioner. Officials issue licenses and other approvals if the applicant pays them under the counter, etc.

The first victims in such a society are the poor. Lack of finances denies them access to education or medical care. Those who rule over them often oppress them. National riches are misappropriated—squandered by those in authority. The powerless poor, with no access to "the system," end up exploited, treated unfairly, and abused. Corrupt practices are not punished. Honesty appears to be unrewarded. People begin to perceive all riches and wealth negatively as dishonest gain. This state of affairs contradicts God's intention.

In the Old Testament, especially during the patriarchal period, wealth was often perceived as a sign of God's favor and blessing. "Riches are initially success guaranteed by God to those who observe the laws of the covenant."[3] This positive view of riches is also a concept in Wisdom tradition. For instance, Job received a double reward after proving himself righteous and faithful before God.[4] By contrast,

---

[3]Conrad Boerma, *The Rich, the Poor and the Bible* (Philadelphia: Westminster, 1980) 11.

[4]Job 42:10.

some Old Testament passages state that poverty may result either from God's punishment for violating the Law[5] or from laziness.[6]

But in a corrupt society, these concepts of riches and poverty are inverted. The rich are in fact often those who transgress the laws of God and society, while the poor suffer as victims of the selfishness and covetousness of others. This reversed situation was already known in later Old Testament history, when God condemned the rich and declared himself the defender of the poor and oppressed.[7]

## Corruption in Cambodian Society

In Cambodia, corruption is not a new problem. It is part of traditional political mentality. Each "key position" is a "benefit" that one must purchase by money or gift.

We must, however, make distinction between "corruption in high levels" and "small day-to-day corruption." The first is practiced by those who unscrupulously squander national resources. They neither worry about national interest nor concern themselves with the well-being of the poor. This kind of corruption needs to be condemned energetically, not only by individuals, but also by moral forces such as Christian churches.

The second category of corruption concerns ordinary day-to-day transactions in society—e.g., paying an official to obtain papers, or a policeman an imaginary "toll" in order to continue traveling. Fulltime employment should enable someone to feed his family. At the present, in order to live honorably, an average family in Phnom Penh needs a monthly income of US $200. But a schoolteacher, policeman, or soldier earns less than US $50 per month. How can they increase their income and provide honestly for their families? From a Christian moral perspective, I think it is hard to condemn someone involved in corruption in order to feed his family, without trying to find means of helping him meet his daily needs.

---

[5]Lev 26:14–26; Deut 15:24.

[6]Prov 6:6–11.

[7]Ex 22:21–27; 23:6-7.

Another act of giving is worth mentioning here that in itself is not fraud, but when misused could easily become so. In traditional societies, especially in Asia, a "gratuity" becomes part of interpersonal relations between those who occupy a position of authority and those who do not. In Cambodian society, one never goes to see another person for a favor with empty hands. The "gift" is part of elementary courtesy. However, one must make the distinction between a "gift" to influence the decision and a "gift" as an act of gratitude. The gap between these two is so narrow and slippery that we must rely on much wisdom when we find ourselves in such a situation.

For instance, all of us are aware that local authorities often require Christians to pay $500 for permission to open a church or a Christian ministry. I think paying $500 to a village chief for his personal gain in order to obtain authorization for evangelism, church planting, or other holistic ministry, is reprehensible. But if the law requires you pay this amount into local administrative coffers, this entails no corruption. After you get the license, you are free to offer a gift to the village chief as recognition for the service he has provided, and I think this is culturally acceptable.

We must keep in mind that corruption takes place when a gift influences the decision of its recipient.

## The Christian Attitude and Biblical Teaching toward Corruption

In *Christian Social Ethics, Exerting Christian Influence*,[8] Rasmussen describes two categories of reaction vis-à-vis the problem of corruption.

1. Righteous indignation: Those who react this way consider themselves blameless. They separate society in two exclusive classes: the bad and the good, but forget that all human hearts contain a mixture of both.

---

[8]Albert Terrill Rasmussen, *Christian Social Ethics, Exerting Christian Influence* (Englewood Cliffs, New Jersey: Prentice-Hall, 1956).

2. Cynical Complacency: Those who react this way oppose the above moralist attitude, and excuse corruption as simply a part of human nature. They regard corruption as a reality of life, and therefore adopt an attitude of complacency. They hold this cynical and conformist attitude, and tend to compare corruption in their society to the worst ones.

I believe that as Christians we should react to this problem with humble recognition of our own involvement, rather than considering ourselves innocent and only blaming others. Instead of either condemning or ignoring the problem, Christians should actively critique the morality of the society we belong to, while simultaneously sharing responsibility and guilt.

Scripture clearly states God's view of corruption:

"Do not pervert justice or show partiality. Do not accept a bribe, for a bribe blinds the eyes of the wise and twists the words of the righteous."[9]

Israel's prophets urged justice for all of God's people. They considered corruption as an offense against the justice of God, and announced that such practices would incur punishment from God. They condemned these evil practices, and called for repentance. Amos said:

You trample on the poor
    and force him to give you grain.
Therefore, though you have built stone mansions,
    you will not live in them;
though you have planted lush vineyards,
    you will not drink their wine.
For I know how many are your offenses
    and how great your sins.
You oppress the righteous and take bribes
    and you deprive the poor of justice in the courts.
Therefore the prudent man keeps quiet in such times,
    for the times are evil.
Seek good, not evil,
    that you may live.

---

[9]Deut 16:19; Ex 23:8.

Then Yahweh God Almighty will be with you,
just as you say he is.
Hate evil, love good;
maintain justice in the courts.
Perhaps Yahweh God Almighty will have mercy
on the remnant of Joseph.[10]

## Conclusion

When living in a society where corruption has engrained itself in the culture, the Christian should not only condemn the practice, but also individually reflect God's holiness through his or her honest lifestyle. There is often a significant price to pay to be honest.

We must also highlight the value of work as the only valid means to gain income, and as one of the best remedies against corruption and poverty.

Corruption is more than a personal moral issue; it is a national ill that cries out to be cured. As Christians we long for a society free from corruption. Churches are often shy in denouncing this evil, even as it continues to spread, fattening the wealthy and emaciating the poor. Although a minority in this country, we should act as parapets against corruption in society, taking stands clearly. We must, on the one hand, unite to fight all forms of corruption, and on the other, struggle proactively against corruption through our holistic ministries. Throughout history, the church of Christ has always cared for the poor and needy. The church of Cambodia is not exempt from this calling. Our church is growing, and it is now time for us to aspire to maturity. Instead of "delegating" NGO's to fulfill our duties towards to poor, the Cambodian church must become more responsible. Proclamation of the gospel and the concern for the needy must go together.

[10]Amos 5:11–15.

សំណុំនិក្ខេបបទ ៤/២ (កក្កដា ២០០៣)៖ ៥៦-៦៦

# ទស្សនៈគ្រីស្ទបរិស័ទ ចំពោះអំពើពុករលួយ



*បណ្ឌិត សុខ ញ៉ិបអារុណា*

អំពើពុករលួយ តែងតែមានគេអនុវត្តជាទូទៅនៅក្នុងប្រទេសកម្ពុជា ។ សូម្បីតែអ្នកមានអាជីពរដែលគួរឲ្យគោរពយ៉ាងខ្ពស់ ដូចជា គ្រូបង្រៀន វេជ្ជបណ្ឌិត និងតុលាការជាដើម ក៏មានការប៉ះពាល់ដល់ជំងឺនេះដែរ ។ អំពើពុករលួយក្លាយទៅជាធម្មតាទៅហើយ មិនថាចំពោះគ្រីស្ទបរិស័ទជាតិ ឬអន្តរជាតិនោះឡើយ ។ ពួកគេរួមចំណែកនៅក្នុងការនេះដោយមិនដឹងខ្លួន (មានគ្រីស្ទបរិស័ទមួយចំនួនតូចអនុវត្តអំពើពុករលួយនេះទុកដូចជាផ្នែកមួយនៃយុទ្ធសាស្ត្ររបស់គេដើម្បី "ពង្រីកអាណាចក្រព្រះ" ។

ដោយព្រោះព្រះត្រាស់ហៅយើងឲ្យរស់នៅក្នុងសង្គមនេះ យើងត្រូវតែឆ្លុះបញ្ចាំងនៅក្នុងបញ្ហានេះចេញពីទស្សនៈរបស់យើងផ្ទាល់ ជាជាងធ្វើជាមិនដឹងមិនឮ ឬមើលរំលង ។

## សកលភាពនៃអំពើពុករលួយ

អំពើពុករលួយ ជាបាតុភូតទូទៅនៅក្នុងសង្គម ដែលគ្រប់សង្គមទាំងអស់បានជួបប្រទះអស់រយៈកាលជាច្រើនឆ្នាំកន្លងទៅហើយនៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សជាតិ ។ វប្បធម៌នីមួយៗមាននិយមន័យរបស់គេចំពោះអំពើពុក រលួយ ប៉ុន្តែគ្រប់គ្នាយល់ថា វាជារឿងអសីលធម៌ ។

អ្នកខ្លះឲ្យនិយមន័យទៅលើអំពើពុករលួយថា ជាការប្រើបុណ្យសក្តិសាធារណៈសំរាប់ផលប្រយោជន៍ខ្លួនឯង ។ ប៉ុន្តែអ្នកខ្លះឲ្យអត្ថន័យថា ជាការបន្លំដល់នរណាម្នាក់ដោយសារភារកិច្ចរបស់ខ្លួន ។ កាលពីដំបូង គេរាប់វាថាជាសំណូក តែក្រោយមកវាក្លាយទៅជាជំនួនទៅវិញ ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ការទាំងពីរនេះជាអំពើទុច្ចរិតទាំងអស់ ។

ប្រសិនបើយើងពិនិត្យត្រឡប់ទៅក្រោយវិញ អំពើពុករលួយចាប់ផ្តើមឡើងតាំងតែពីការចាប់ផ្តើមនៃប្រវត្តិសាស្ត្រមនុស្ស ។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ នៅពេលដែលហោរាសាំយ៉ូអែលនិយាយទៅកាន់រាស្ត្រអ៊ីស្រាអែល បន្ទាប់ពីគេបានជ្រើសរើសស្តេចសំរាប់ពួកគេរួចមក គាត់បានសួរថា "តើខ្ញុំបានទទួលសំណូកពីដៃអ្នកណាដើម្បីឲ្យខ្ញុំធ្មេចភ្នែក"[១] សំណួររបស់សាំយ៉ូអែលនេះបង្ហាញឲ្យឃើញថា ពួកគេបានអនុវត្តការនេះតាំងតែពីបុរាណកាលនៃពួកអ៊ីស្រាអែលមកម៉្លេះ ។ ក្រោយមកពេលដែលស្តេច យេហូសាផាត តែងតាំងពួកចៅហ្វាយសំរាប់ពួកយូដា ទ្រង់បានលើកទឹកចិត្តពួកគេ "ចូរកាត់ក្តីដោយប្រុងប្រយ័ត្ន ដ្បិតគ្មានសេចក្តីទុច្ចរិតណានៅនឹង ព្រះយេហូវ៉ា ជាព្រះនៃយើងរាល់គ្នាឡើយ ក៏គ្មានសេចក្តីលំអៀងទៅខាងឯណា ឬស៊ីសំណូកផង" ។[២]

---

[១] *១ សាំយូអែល ១២:៣*

[២] *២ របាក្សត្រ ១៩:៧*

នៅក្នុងប្រវត្តិសាស្ត្រ អំពើពុករលួយបានចាប់ផ្តើមជាបទល្មើសតាមរយៈការបោះឆ្នោត និងរឿងនយោបាយ ។ បេក្ខជននីមួយៗទិញសន្លឹកឆ្នោតដោយទឹកប្រាក់ ។ អ្នកបំរើឯកជនសូកសំណូករកឋានៈខ្ពស់ ដើម្បីឲ្យពួកគេបានទទួលកំរៃច្រើន និងមានកិត្តិយស ។ ការអនុវត្តន៍នេះ ត្រូវបានគេទទួលស្គាល់តាំងតែពីសម័យចក្រភពរ៉ូមមកម្ល៉េះ ។ រ៉ូម៉ាំងបានចេញច្បាប់ដើម្បី ដាក់ទារុណកម្ម ឬកំចាត់មនុស្សដែលអនុវត្តអំពើពុករលួយនេះ ។ នៅក្នុងសម័យបុរាណរបស់ក្រិក អំពើពុករលួយតែងតែមានការទាក់ទងទៅនឹង រឿងតុលាការ ។ មានអ្នកខ្លះសូកលុយដល់អ្នកជំនាញខាងច្បាប់ ដើម្បីទំលាក់ញត្តិចោលចេញពីភស្តុតាងនៅនឹងមុខតែម្តង ឬក៏ឲ្យលុយទៅមន្ត្រីរាជការក្នុងមធ្យោបាយមិនត្រឹមត្រូវណាមួយ ។

សព្វថ្ងៃនេះមានប្រទេសជាច្រើន មានច្បាប់ប្រឆាំងទៅនឹងការក្លែងបន្លំនៅក្នុងការបោះឆ្នោត ឬនៅក្នុងនយោបាយរដ្ឋបាល និងរឿងដែលទាក់ទងទៅនឹងច្បាប់ផ្សេងៗ ។ នៅក្នុងសង្គមទំនើប ការអនុវត្តន៍អំពើពុករលួយអាចកើតមានឡើងនៅក្នុងប្រព័ន្ធសេដ្ឋកិច្ច ដូចជាការចាត់ចែងថវិកា ឬអំពើពុករលួយខាងជំនួញ ។ អំពើពុករលួយខាងជំនួញគឺពេលខ្លះបានអនុវត្តនៅក្នុងកិរិតអន្តរជាតិ ។ អ្នកជំនួញសូកលុយរកទុយយោ ឬទីផ្សារ ដើម្បីឲ្យពួកគេអាចទទួលផលប្រយោជន៍បានកាន់តែច្រើនថែមទៀត ។ ពួកគេ ពេលខ្លះបង្កើនការចំណេញរបស់ពួកគេដោយប្រើរបស់ដែលគ្មានគុណភាព និងបន្លំគុណភាពនៅក្នុងការងារដែលគេផ្តល់ឲ្យ ។

រដ្ឋាភិបាលខ្លះតែងតែប្រឆាំងទៅនឹងអំពើពុករលួយ ពីព្រោះវាធ្វើឲ្យខូចខាតដល់ផ្នែកហិរញ្ញវត្ថុ ។ អ្នកដទៃទៀតប្រឆាំង ដោយព្រោះវានាំទៅរកភាពខ្វះខាត (ប្រជាពលរដ្ឋអាចទទួលអ្វីៗតាមសេចក្តីត្រូវការបាន លុះត្រាតែគេសូកមន្ត្រីឲ្យចាប់អារម្មណ៍មកលើគេ) ។

ហេតុផលដែលគេធ្វើសហប្រត្តិបត្តិការប្រឆាំងទៅនឹងអំពើពុករលួយដោយព្រោះតែវាកាត់បន្ថយការចំណេញ ។ អ្នកជំនាញផ្លូវច្បាប់ប្រឆាំងនឹងអំពើ

ស៊ីសំណូក ព្រោះតែវាល្មើសទៅនឹងគោលការណ៍នៃសិទ្ធិសេរីភាព និង យុត្តិធម៌ស្មើគ្នាសំរាប់មនុស្សទាំងអស់ មិនមែនសំរាប់តែអ្នកសូកនោះទេ ។

ស្ថាប័នគ្រីស្ទបរិស័ទគិតថា អំពើពុករលួយ គឺជាបញ្ហានៃក្រមសីលធម៌។ ដូច្នេះពួកគេបដិសេធការអនុវត្តន៍បែបនេះ ដូចជារបៀបនៃការធ្វើបាបផ្សេងៗផងដែរ ។

## ទ្រព្យសម្បត្តិ ភាពក្រីក្រ និងអំពើពុករលួយ

នៅក្នុងសង្គមជាច្រើន អំពើពុករលួយមានសឹងតែគ្រប់កំរិតទាំងអស់ ចាប់តាំងពីមួយថ្ងៃទៅមួយថ្ងៃ រហូតទៅដល់កំរិតនៃការសំរេចចិត្តដ៏ខ្ពស់ ។ នៅក្នុងសង្គមដែលធាតុទាំងបីនេះ "ទ្រព្យសម្បត្តិ ភាពក្រីក្រ និងអំពើពុករលួយ" វេញចូលគ្នា យើងមិនអាចបែងចែកធាតុភូតទាំងបីនេះដាច់ចេញពីគ្នាបានឡើយ ។ អំពើពុករលួយក្លាយទៅជារបស់ដែលកប់យ៉ាងជ្រៅទៅក្នុង "ប្រព័ន្ធ" នៃការសំរេចកិច្ចការងារអ្វីមួយ ។ ឪពុកម្តាយផ្តល់សំណូកដល់គ្រូ ដើម្បីឲ្យគ្រូនោះផ្តល់ពិន្ទុល្អដល់កូនរបស់ខ្លួន ឬអនុញ្ញាតឲ្យកូនរបស់ខ្លួនអាចទទួលសញ្ញាប័ត្របាន ។ មន្ត្រីផ្សេងៗអាចចេញច្បាប់ឲ្យ និងយល់ព្រមអ្វីមួយ លុះត្រាតែបេក្ខជននោះសូកពួកគេជាមុន ។ល។

ជនរងគ្រោះដំបូងនៅក្នុងសង្គមបែបនេះគឺជនក្រីក្រ។ ថវិការារាំងពួកគេចេញឆ្ងាយពីការសិក្សា ឬការគាំពារព្យាបាលផ្សេងៗ ។ អស់អ្នកដែលគ្រប់គ្រងនៅពីលើគេតែងតែគាបសង្កត់ពួកគេ ។ ទ្រព្យសម្បត្តិជាតិត្រូវបានអ្នកមានអំណាចប្រើប្រាស់មិនត្រឹមត្រូវ ហើយចាយវាយខ្ជះខ្ជាយ ។ ជនក្រីក្រ ដែលគ្មានអំណាចដែលមិនអាចតភ្ជាប់ទៅនឹង "ប្រព័ន្ធ" បានក៏ត្រូវបញ្ចប់ទៅដោយអ្នកដទៃក្រេបយកផលប្រយោជន៍ទាំងអស់ ពួកគេទទួលនូវភាពលំអៀង និងការកេងប្រវ័ញ្ចន៍។ ការប្រព្រឹត្តិអំពើពុករលួយមិនត្រូវបាន ដាក់ទោសឡើយ ។ ភាពស្មោះត្រង់ដូចជាមិនត្រូវបានទទួលរង្វាន់អ្វីសោះ ។ មនុស្សចាប់ផ្តើមយល់ដឹងពីអភិជន

ភាព និងទ្រព្យសម្បត្តិក្នុងផ្លូវអវិជ្ជមាន នៅពេលដែលភាពមិនស្មោះត្រង់រិតតែទទួលផលចំណេញ ។ ចំពោះរឿងនេះ ពិតជាប្រឆាំងទៅនឹងព្រះហឫទ័យរបស់ព្រះហើយ ។

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ជាពិសេសនៅក្នុងសម័យបិតុធិបតេយ្យ ទ្រព្យសម្បត្តិត្រូវបានទទួលស្គាល់ថា ជាសញ្ញាដែលព្រះសព្វព្រះហឫទ័យ និងជាព្រះពរ ។ "ទ្រព្យសម្បត្តិ គឺជាសញ្ញានៃការទទួលជោគជ័យដែលព្រះប្រទានពរដល់អស់អ្នកណាដែលរក្សាក្រិត្យវិន័យនៃការតាំងសញ្ញារបស់ព្រះអង្គ" ។[៣] គំនិតវិជ្ជមាននៃទ្រព្យសម្បត្តិបែបនេះ គឺជាគំនិតនៅក្នុងទំនៀមទំលាប់នៃគតិបណ្ឌិត ។ ឧទាហរណ៍ ដូចជាយ៉ូបទទួលព្រះពរទ្វេមក ពីព្រះបន្ទាប់ពីគាត់ពិសោធខ្លួនគាត់នៅចំពោះព្រះជាម្ចាស់ថា គាត់សុចរិត និងស្មោះត្រង់ ។[៤] ផ្ទុយទៅវិញ ខព្រះគម្ពីរសញ្ញាចាស់ខ្លះចែងថា ភាពក្រីក្រប្រហែលជាលទ្ធផលនៃការដាក់ទារុណកម្មមកពីព្រះដោយព្រោះការល្មើសនឹងក្រិត្យវិន័យ[៥] របស់ព្រះអង្គ ឬក៏មកពីភាពខ្ជិលច្រអូស ។[៦]

ប៉ុន្តែនៅក្នុងសង្គមពុករលួយ ទស្សនៈស្តីអំពីទ្រព្យសម្បត្តិ និងភាពក្រីក្រ គឺមានភាពផ្ទុយគ្នា ។ តាមពិតអ្នកមាន គឺជាអស់អ្នកដែលតែងតែល្មើសទៅនឹងច្បាប់របស់ព្រះ និងសង្គមចំណែកឯអ្នកក្រវិញរងទុក្ខដូចជាជនរងគ្រោះក្រោមភាពអាត្មានិយម និងភាពលោភលន់របស់អ្នកដទៃ ។ ហេតុការណ៍ផ្ទុយគ្នានេះត្រូវបានទទួលស្គាល់នៅក្នុងប្រវត្តិសញ្ញាចាស់ ក្រោយពេលដែលព្រះកាត់ទោសអ្នក

---

[៣] *ខេន់ ប៊ីម៉ោ ដែលមានចំណងជើងថា អ្នកមាន អ្នកក្រ និងព្រះគម្ពីរ (ភីឡាដែលភី: វេសមិនស្ទ័រ ១៩៨០) ១១*

[៤] *យ៉ូប ៤២:១០*

[៥] *លេវីវិន័យ ២៦:១៤-២៦; ចោទិយកថា ១៥:២៤*

[៦] *សុភាសិត ៦:៦-១១*

មាន ហើយប្រកាសអង្គទ្រង់ជាអ្នកការពារអ្នកក្រីក្រ និងអ្នកដែលត្រូវគេគាបសង្កត់ ។[៧]

## ការពុករលួយនៅក្នុងសង្គមកម្ពុជា

នៅក្នុងប្រទេសកម្ពុជា អំពើពុករលួយមិនមែនជាបញ្ហាថ្មីទេ ។ វាគឺជាផ្នែកមួយនៃទំនៀមទំលាប់ និងគំនិតនយោបាយទៅហើយ ។ នៅក្នុង "ឋានៈសំខាន់នីមួយៗ" គឺតែងតែមាន "ផលប្រយោជន៍" ដោយព្រោះម្នាក់ៗទទួលបានទឹកលុយ ឬអំណោយ ។

ទោះបីយ៉ាងណាក៏ដោយ យើងត្រូវតែបែងចែករវាង "ការពុករលួយនៅក្នុងកំរិតខ្ពស់" និង "ការពុករលួយប្រចាំថ្ងៃ" ។ ការពុករលួយ ទីមួយគឺ អនុវត្តដោយអស់អ្នកដែលប្រើប្រាស់ខ្ជះខ្ជាយប្រភពធនធានជាតិ ។ ពួកគេមិនដែលខ្វល់ខ្វាយពីរឿងជាតិ ឬគិតគូរដល់ជនក្រីក្រនោះទេ ។ ភាពពុករលួយប្រភេទនេះ ត្រូវតែថ្កោលទោសយ៉ាងស្វាហាប់បំផុត មិនមែនដោយបុគ្គលណាម្នាក់ ប៉ុន្តែដោយក្រុមដែលមានសីលធម៌ខ្ពស់ដូចជាពួកជំនុំគ្រីស្ទបរិស័ទជាដើម ។

ការពុករលួយ ទីពីរគឺទាក់ទងទៅនឹងរឿងសាមញ្ញរស់ថ្ងៃនៅក្នុងសង្គម ឧទាហរណ៍ សូកលុយមន្ត្រី ដើម្បីចង់បានក្រដាសស្នាមអ្វីមួយ ឬដល់ប៉ូលីស ដើម្បីបាន "ពន្ធ" ក្លែងក្លាយសំរាប់ឲ្យគេអាចធ្វើដំណើរទៅមុខទៀតបាន ។ ការធ្វើការងារពេញពេលគួរតែអាចចិញ្ចឹមគ្រួសាររបស់ខ្លួនបាន ។ នៅក្នុងបច្ចុប្បន្នកាលនេះ ដើម្បីឲ្យរស់មានកិត្តិយស មធ្យមភាគនៃគ្រួសារមួយដែលត្រូវការចំណូលក្នុងមួយខែគឺ ២០០ដុល្លា ។ ប៉ុន្តែគ្រូបង្រៀន ប៉ូលីស ឬទាហាន ទទួលបានតិចជាង ៥០ដុល្លា ក្នុងមួយខែ ។ តើធ្វើដូចម្តេចដើម្បីឲ្យគេបង្កើនការចំណូលរបស់គេ ហើយចិញ្ចឹមក្រុមគ្រួសាររបស់គេដោយស្មោះត្រង់បាន? សំរាប់ទស្សនៈសីលធម៌

---

[៧] និក្ខមនំ ២២:២១-២៧; ២៣:៦-៧

របស់គ្រីស្ទបរិស័ទ ខ្ញុំគិតថា វាជាការលំបាកណាស់នៅក្នុងការដែលយើងថ្កោលទោសនរណាម្នាក់ ដែលពាក់ព័ន្ធនៅក្នុងអំពើពុករលួយនេះ ដោយព្រោះតែគេត្រូវចិញ្ចឹមក្រុមគ្រួសាររបស់គេ ដោយយើងមិនបានព្យាយាមរកមធ្យោបាយជួយគេឲ្យអាចដោះស្រាយជីវភាពគ្រួសារគ្រប់គ្រាន់បាន ។

សកម្មភាពនៃការជួយកន្លែងនេះ គឺត្រឹមត្រូវ វាមិនមែនជាការបន្លំទេ ប៉ុន្តែនៅពេលដែលយើងប្រើខុសគឺពិតជាក្លាយទៅជាសំណូកហើយ ។ នៅក្នុងទំនៀមទំលាប់នៃសង្គមផ្សេងៗ ជាពិសេសនៅក្នុងអាស៊ី "ថ្លៃទឹកតែ" ក្លាយទៅជាទំនាក់ទំនងរវាងអ្នកដែលមានឋានៈនៅក្នុងអំណាច និងអ្នកដែលគ្មាន ។ នៅក្នុងសង្គមកម្ពុជាគ្មាននរណាម្នាក់ទៅរកម្នាក់ផ្សេងជួយដោយដៃទទេនោះទេ ។ "អំណោយ" គឺជាផ្នែកមួយនៃការគួរសមយ៉ាងសាមញ្ញ ។ ទោះបីយ៉ាងណាក៏ដោយ ក៏យើងត្រូវតែធ្វើការបែងចែកឲ្យបានច្បាស់អំពីអ្វីដែលជា "អំណោយ" ដែលជះឥទ្ធិពលដល់ការសំរេចចិត្តនិង "អំណោយ" ដែលជាការដឹងគុណ ។ ចន្លោះរវាងពាក្យទាំងពីរនេះ គឺវាមានភាពចង្អៀតណាស់ ហើយក៏មានភាពរអិលដែរ ដែលយើងត្រូវការប្រាជ្ញាយ៉ាងច្រើននៅពេលដែលជួបនៅក្នុងកាលៈទេសៈបែបនេះ ។

ឧទាហរណ៍ យើងទាំងអស់គ្នាដឹងហើយថា រដ្ឋអំណាចនៅក្នុងស្រុកតំរូវឲ្យគ្រីស្ទបរិស័ទបង់ ២៥០ ដល់ ៥០០ ដុល្លា សំរាប់ច្បាប់អនុញ្ញាតឲ្យបើកព្រះវិហារ ឬពន្ធកិច្ចគ្រីស្ទបរិស័ទ ។ ខ្ញុំគិតថា បង់ ៥០០ដុល្លា ដល់រដ្ឋអំណាចដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីឲ្យបានច្បាប់ផ្សាយដំណឹងល្អ បង្កើតពួកជំនុំ ឬពន្ធកិច្ចគ្រប់ជ្រុងជ្រោយផ្សេងៗទៀត គឺជាការគួរឲ្យរិះគន់យ៉ាងខ្លាំង ។ ប៉ុន្តែប្រសិនបើច្បាប់តំរូវឲ្យអ្នកបង់ក្នុងតំលៃនេះដល់កិច្ចរដ្ឋបាលពិតប្រាកដមែននោះ គឺមិនមែនជាអំពើពុករលួយទេ ។ បន្ទាប់ពីអ្នកទទួលច្បាប់ នោះអ្នកមានសេរីភាពក្នុងការជូនអំណោយដល់មេភូមិទុកដូចជាការដឹងគុណសំរាប់កិច្ចការដែលគាត់បានផ្តល់ឲ្យយ៉ាងនេះខ្ញុំគិតថា ទម្លាប់អាចទទួលយកបាន ។

យើងត្រូវតែរក្សានៅក្នុងគំនិតរបស់យើងថា អំពើពុករលួយកើតឡើង នៅពេលដែលអំណោយជះឥទ្ធិពលទៅលើការសំរេចចិត្តរបស់អ្នកដែលធ្វើ ។

## ឥរិយាបថរបស់គ្រីស្ទបរិស័ទ និងសេចក្ដីបង្រៀនរបស់ព្រះគម្ពីរទាក់ទងនឹងអំពើពុករលួយ

នៅក្នុងសៀវភៅ "សីលធម៌សង្គមគ្រីស្ទបរិស័ទ និងការប្រើឥទ្ធិពលរបស់គ្រីស្ទបរិស័ទ"[៨] លោក រ៉ាសប៉ូសេន ពិពណ៌នាអំពីកត្តាពីរយ៉ាងនៃសកម្មភាពទំនាក់ទំនងទៅនឹងបញ្ហាអំពើពុករលួយ ។

១. មិនថ្លៃថ្នូរក៏ហីទៅចុះ ឲ្យតែសុចរិតៈ អស់អ្នកដែលបញ្ចេញសកម្មភាពបែបនេះគិតខ្លួនឯងថាល្អឥតខ្ចោះ ។ ពួកគេញែកសង្គមជាចំហាពីរថ្នាក់ៈ ល្អ និង អាក្រក់ ប៉ុន្តែភ្លេចថា ចិត្តរបស់មនុស្សមានការទាំងពីរលាយគ្នា ។

២. ការអាក្រក់ជារឿងធម្មតាៈ អស់អ្នកដែលបញ្ចេញសកម្មភាពបែបនេះប្រឆាំងទៅនឹងគំនិតខាងលើ ហើយលើកលែងដល់អំពើពុករលួយថា នេះគឺជារឿងធម្មតារបស់មនុស្ស ។ ពួកគេយល់ថា អំពើពុករលួយ គឺជាការពិតនៃជីវិត ដូច្នេះពួកគេស៊ុំគ្រលំយ៉ាងស្រួលជាមួយអំពើពុករលួយ ។ ពួកគេប្រកាន់យកគំនិតនេះ ហើយមានឥរិយាបថសំរបសំរួល ហើយចូលចិត្តប្រៀបធៀបអំពើពុករលួយនៅក្នុងសង្គមរបស់ខ្លួនទៅនិងសង្គមមួយទៀតដែលអាក្រក់ជាងនេះ ។

ខ្ញុំជឿថា ក្នុងនាមជាគ្រីស្ទបរិស័ទ យើងត្រូវតែបញ្ចេញសកម្មភាពចំពោះបញ្ហានេះជាមួយការទទួលស្គាល់ ដោយភាពបន្ទាបខ្លួននៃការចូលរួមរបស់យើងជាជាងយល់ថា ខ្លួនឯងមិនដឹង ហើយបន្ទោសអ្នកដទៃ ។ ជំនួសឲ្យការថ្កោលទោស ឬធ្វើមិនដឹងមិនឮចំពោះបញ្ហានេះ គ្រីស្ទបរិស័ទត្រូវតែចូលរួមយ៉ាងសកម្ម

---

*[៨] អាល់ប៊ឺត ធារីល រ៉ាស់ប្ញសេនក្រុមសីលធម៌សង្គមរបស់គ្រីស្ទបរិស័ទ បញ្ចូលឥទ្ធិពលគ្រីស្ទបរិស័ទ (អិនជិលវូដ នៅក្នុងរដ្ឋ នូជើស៊ីៈ ប្រ៊ីនធីស ហាល ១៩៥៦)*

ក្នុងការទិតៀនសីលធម៌សង្គមរបស់យើងក្នុងពេលជាមួយគ្នា យើងត្រូវតែចែកចាយការទទួលខុសត្រូវ និងកំហុសនេះ ។

ព្រះគម្ពីរចែងយ៉ាងច្បាស់ពីទស្សនៈរបស់ព្រះចំពោះអំពើពុករលួយៈ "មិនត្រូវបង្វែរសេចក្ដីយុត្តិធម៌ឡើយ ក៏មិនត្រូវលំអៀងចិត្តទៅខាងណា ឬស៊ីសំណូកឲ្យសោះ ដ្បិតសំណូកជាការនាំឲ្យបិទភ្នែកអ្នកប្រាជ្ញ ហើយក៏បង្ខូចពាក្យសំដីរបស់មនុស្សសុចរិតផង" ។[៩]

ហោរារបស់ពួកអ៊ីស្រាអែល ប្រកាសឲ្យមានសេចក្ដីយុត្តិធម៌ដល់អស់ទាំងរាស្ត្រអ៊ីស្រាអែល ។ ពួកគេយល់ថា អំពើពុករលួយ ជាសេចក្ដីអាម៉ាស់បំផុតដែលប្រឆាំងទៅនឹងភាពយុត្តិធម៌របស់ព្រះ ហើយប្រកាសថា អ្នកណាពុករលួយ អ្នកនោះត្រូវទទួលការជំនុំជំរះមកពីព្រះ ។ ពួកគេកាត់ទោសអំពើពុករលួយ ហើយប្រកាសឲ្យមានការប្រែចិត្ត ។ អេម៉ុសនិយាយថាៈ ដូច្នេះដោយព្រោះឯងរាល់គ្នាតែងញាំញីពួកក្រ ហើយរឹបយកស្រូវពីគេ បានជាឯងរាល់គ្នានឹងសង់ផ្ទះដោយថ្មដាប់ តែមិនបានអាស្រ័យនៅក្នុងផ្ទះនោះទេ ឯងរាល់គ្នានឹងដាំចំការទំពាំងបាយជូរដ៏គាប់ចិត្ត តែមិនបានផឹកស្រាទំពាំងបាយជូរពីនោះឡើយ ដ្បិតអញដឹងហើយថា អំពើរំលងរបស់ឯងរាល់គ្នាមានសន្ធឹកណាស់ ហើយអំពើបាបរបស់ឯងរាល់គ្នាក៏មានទំងន់ពេកផង គឺឯងរាល់គ្នាហើយជាពួកអ្នកដែលបៀតបៀនមនុស្សសុចរិត ហើយស៊ីសំណូក ព្រមទាំងបង្វែរមនុស្សកំសត់ទុគ៌តមិនឲ្យសំរេចតាមអំណាចច្បាប់ ហេតុនោះមនុស្សដែលមានគំនិតវាងវៃនឹងស្ងៀមនៅក្នុងគ្រាយ៉ាងនេះ

---

[៩] *ចោទិយកថា ១៦:១៩; និក្ខមនំ ២៣:៨*

ដ្បិតជាគ្រាអាក្រក់ហើយ ។ ចូរស្វែងរកសេចក្ដីល្អ កុំរកសេចក្ដីអាក្រក់ឡើយ ដើម្បីឲ្យឯងរាល់គ្នាបានរស់នៅយ៉ាងនោះ ព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវារទ្រង់នឹងគង់នៅជាមួយឯងជាពិតដូចជាឯងធ្លាប់ហើយថា ចូរស្អប់អំពើអាក្រក់ ហើយស្រឡាញ់អំពើល្អវិញ ចូរតាំងឲ្យមានសេចក្ដីយុត្តិធម៌នៅត្រង់ទ្វារក្រុងចុះ នោះប្រហែលជាព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវារ ទ្រង់នឹងប្រព្រឹត្តដល់សំណល់នៃពួកយ៉ូសែបដោយករុណាគុណទេដឹង ។[១០]

## សរុបសេចក្ដី

នៅពេលដែលការរស់នៅក្នុងសង្គមដែលមានអំពើពុករលួយបញ្ចូលខ្លួនទៅក្នុងវប្បធម៌ គ្រីស្ទបរិស័ទមិនមែនគ្រាន់តែថ្កោលទោសការអនុវត្តន៍បែបនេះតែប៉ុណ្ណោះទេ ប៉ុន្តែម្នាក់ៗឆ្លុះបញ្ចាំងទៅលើភាពបរិសុទ្ធរបស់ព្រះតាមរយៈជីវភាពរស់នៅរបស់គេ ។ តែងតែមានតំម្លៃសំខាន់ណាស់ដែលយើងត្រូវទទួលក្នុងភាពស្មោះត្រង់របស់យើង ។

ដូចគ្នាដែរ យើងត្រូវបង្ហាញពីតំម្លៃនៃការងារដែលត្រឹមត្រូវ គឺសមស្របទៅតាមលទ្ធផលចំណេញដែលខ្លួនគួរទទួល ហើយជាមធ្យោបាយដោះស្រាយមួយប្រសើរបំផុតប្រឆាំងទៅនឹងអំពើពុករលួយ និងភាពក្រីក្រ ។

អំពើពុករលួយ ជារឿងមួយដែលលើសពីសីលធម៌ផ្ទាល់ខ្លួន គឺជាជំងឺជាតិដែលកំពុងស្រែករកការធ្វើឲ្យជា ។ ក្នុងនាមជាគ្រីស្ទបរិស័ទ យើងស្វែងរកសង្គមណាដែលគ្មានអំពើពុករលួយ ។ ក្រុមជំនុំនីមួយៗតែងតែមានការខ្មាសអៀនក្នុងការបដិសេធការអាក្រក់នេះ ទោះបីជាវានៅតែបន្តរីកសុះសាយធ្វើឲ្យ

---

[១០] *អេម៉ុស ៥:១១-១៥*

អ្នកមានកាន់តែមានឡើងៗ និងធ្វើឲ្យអ្នកក្រកាន់តែទន់ខ្សោយទៅៗ ។ ទោះបីគ្រីស្ទបរិស័ទមានចំនួនតិចនៅក្នុងប្រទេសក៏ដោយ ក៏យើងត្រូវតែបញ្ចេញសកម្មភាពយ៉ាងសកម្មបំផុត ប្រឆាំងទៅនឹងអំពើពុករលួយនៅក្នុងសង្គមដោយឈរលើគោលជំហរយ៉ាងច្បាស់លាស់ ។ មួយ យើងត្រូវតែរួបរួមគ្នាប្រយុទ្ធនូវរាល់ទំរង់នៃអំពើពុករលួយ ហើយម្យ៉ាងទៀត យើងត្រូវតស៊ូយ៉ាងសកម្មបំផុត ប្រឆាំងទៅនឹងអំពើពុករលួយតាមរយៈពន្ធកិច្ចគ្រប់ជ្រុងជ្រោយរបស់យើង ។ ឆ្លងកាត់ប្រវត្តិសាស្ត្រកន្លងទៅក្រុមជំនុំព្រះគ្រីស្ទតែងតែយកចិត្តទុកដាក់ដល់អ្នកក្រីក្រ និងអ្នកស្រេកឃ្លាន ។ ក្រុមជំនុំកម្ពុជាមិនអាចលើកលែងពីការការត្រាស់ហៅនេះបានឡើយ ។ ពេលក្រុមជំនុំយើងមានការរីកចំរើន ពេលនោះហើយដែលយើងត្រូវឈានឆ្ពោះទៅរកភាពរឹងមាំ ។ ជំនួសឲ្យការ "ផ្ទេរ" ឲ្យអង្គការក្រៅរដ្ឋាភិបាលធ្វើការដើម្បីជនក្រីក្រ យើងដែលជាក្រុមជំនុំត្រូវតែមានការទទួលខុសត្រូវជាងគេទៅទៀត ។ ការប្រកាសដំណឹងល្អ និងការគិតគូរដល់អ្នកស្រេកឃ្លានត្រូវតែទៅជាមួយគ្នាដោយមិនអាចអត់ពីគ្នាបាន ។

សំណុំធិកឃ្មុំ ៤/២ (កក្កដា ២០០៣)៖ ៦៧-៧២



*លោក អ៊ួន សិលា*

# ជួបជាមួយលោកគ្រូ សៀង អង់



*លោកគ្រូ សៀង អង់*

លោកគ្រូ សៀង អង់ កើតនៅថ្ងៃទី ១៩ ឧសភា ឆ្នាំ១៩១៨ ក្នុងគ្រួសារកសិករមួយដែលកាន់ជំនឿផ្នែកព្រះពុទ្ធសាសនា នៅក្នុងភូមិឫស្សី ឃុំបារាយណ៍ ស្រុកទ្រាំង ខេត្តតាកែវ ។ គាត់ត្រូវជាកូនរបស់ លោក សៀង ប៉ែត និងអ្នកស្រី អាំ ។ គាត់មានបងប្អូនបង្កើត ៥ នាក់ គឺស្រី ៤ នាក់ និង ប្រុស ១នាក់ ។ គាត់គឺជាកូនទី ៤ ។

នៅឆ្នាំ ១៩៣៤ គាត់បានបួសជាសង្ឃពុទ្ធសាសនាអស់រយៈពេល ៤ វស្សា ។

អរព្រះគុណព្រះជាម្ចាស់ ដែលគាត់មានឱកាសសិក្សាយល់ច្បាស់ផ្នែកពុទ្ធសាសនា លុះដល់ឆ្នាំ ១៩៤២ គាត់បានលាចាកសិក្ខាបទ ។ បន្ទាប់មកបានរៀបការជាមួយ អ្នកស្រី ប៊ុន សុខ ដែលរស់នៅក្នុងភូមិជាមួយគ្នា នៅឆ្នាំ ១៩៤៣ ។ លោកគ្រូបានថ្វាយខ្លួនទទួលជឿព្រះយេស៊ូ ជាមួយ លោកគ្រូ ជុំ ប៉ៀង ដែលជាគ្រូផ្សាយដំណឹងល្អនៅក្នុងនិកាយស៊ីអឹមអេ (C&MA) ។ គាត់បានចូលរៀននៅសាលាព្រះគម្ពីរតាខ្មៅអស់រយៈពេល ៨ឆ្នាំ ។ ក្រោយពីបញ្ចប់ការសិក្សានៅវិទ្យាស្ថានព្រះគម្ពីរនោះរួចមក គាត់បានធ្វើការជាគ្រូផ្សាយដំណឹងល្អជាមួយនិកាយស៊ីអឹមអេ ។

នៅឆ្នាំ១៩៥៤ លោកគ្រូ សៀង អង់ ចេញទៅធ្វើការផ្សាយដំណឹងល្អនៅខេត្ត តាកែវ ។ ការងារបំរើព្រះនៅទីនោះមានការរីកចំរើនយ៉ាងខ្លាំង រហូតដល់មានការចាប់ឃុំខ្លួន ដោយគេនិយាយបង្កាច់លោកគ្រូថា ជាអ្នកបង្អាប់សាសនាព្រះពុទ្ធ ហើយជាអ្នកដែលនាំមនុស្សជាច្រើនឲ្យវង្វេងពីសាសនារបស់ខ្លួន ។ គេបានទាមទារឲ្យគាត់បង់ប្រាក់ចំនួន២,៥០០៛ ។ ប្រាក់សម័យនោះមានតម្លៃច្រើនសន្ធឹកណាស់ ហើយគេបាននិយាយថា បើគ្មានប្រាក់បង់ទេនោះ គេមិនអនុញ្ញាតឲ្យរួចខ្លួនពីការឃុំឃាំងឡើយ ។ ពេលនោះភរិយារបស់គាត់ក៏ខំដើររកខ្ចីលុយពីបងប្អូន ដើម្បីយកទៅបង់ជូនគេតាមពេលដែលគេកំណត់ឲ្យនោះ ។ ប៉ុន្តែអរព្រះគុណព្រះជាម្ចាស់ដែលព្រះអង្គបានធ្វើការអស្ចារ្យក្នុងចិត្តអ្នកដែលទទួលប្រាក់ទាំងអស់នោះ គេហាក់បីដូចជាមានការភ័យខ្លាចយ៉ាងម៉េចមិនដឹងទេ ទើបគេយកប្រាក់ទាំងអស់នោះមកប្រគល់ឲ្យវិញដោយមិនបាត់មួយរៀលសោះ ថែមទាំងនិយាយសុំទោសដល់ លោកគ្រូទៀតផង ។

លុះដល់ឆ្នាំ ១៩៦១ លោកគ្រូចេញទៅបំរើព្រះនៅក្នុងភូមិ ព្រែក ក្រាញ់ ផ្សារស្រែចំ ជើងភ្នំកំចាយ ឃុំទឹកល្អក់ ស្រុកព្រៃនប់ ខេត្តកំពត ។ នៅទីនោះគាត់បានបង្កើតក្រុមជំនុំមួយថ្វាយព្រះអង្គ គឺនៅក្នុងទីរួមខេត្ត កំពត តែម្តង ហើយគាត់បានស្នាក់នៅទីនោះរហូតដល់ឆ្នាំ ១៩៧០ ។

មហាសន្និបាតរបស់គ្រីស្ទបរិស័ទនៅទីក្រុងភ្នំពេញ បានសម្រេចជ្រើសរើសអ្នកស្ម័គ្រចិត្តចេញទៅបំរើព្រះនៅកម្ពុជាក្រោម ។ ពេលនោះ លោកគ្រូបានស្ម័គ្រចិត្តទៅបំរើព្រះនៅខេត្ត ឃ្លាំង កម្ពុជាក្រោម ។ កាលពីមុនពេលចេញទៅមានការសន្យា ពីគណកម្មាធិការកណ្តាលថា នឹងផ្តល់ថវិកាឧបត្ថម្ភប្រចាំខែ តែនៅពេលទៅដល់ទឹកដីថ្មីដែលមិនមែនជាទឹកដីនៃប្រទេសកំណើតរបស់ខ្លួនផង មានការបៀតបៀនផង ថែមទាំងគ្មានថវិកាឧបត្ថម្ភផង (ព្រោះមានបញ្ហាផ្នែកបច្ចេកទេស) ដែលធ្វើឲ្យលោកគ្រូ និងគ្រួសារមានជីវភាពលំបាកលំបិនមែនទែន ។ ពេលនោះគាត់ត្រូវទៅរស់នៅក្នុងភូមិ មនោទេន ស្រុក ព្រែកឫស្សី ខេត្តឃ្លាំង នៅកម្ពុជាក្រោម ។ ដោយសារតែលោកគ្រូធ្លាប់បួសជាសង្ឃផ្នែកព្រះពុទ្ធសាសនា កាលលោកមិនទាន់ទទួលជឿព្រះយេស៊ូនោះ ទើបលោកគ្រូអាចផ្សាយដំណឹងល្អជាមួយនឹងលោកសង្ឃ និងពុទ្ធបរិស័ទខ្មែរក្រោមយ៉ាងងាយស្រួល តែទោះជាយ៉ាងណាក៏ដោយ មានការបៀតបៀនមិនអន់ប៉ុន្មានដែរ ក្នុងឋានៈលោកគ្រូ ជាបេសកជនចេញទៅក្រៅស្រុកទេសរបស់ខ្លួននោះ ។

នៅពេលដែលគាត់ធ្វើការបំរើព្រះនៅទីនោះគ្មានបានទទួលប្រាក់ខែអ្វីទាំងអស់នោះ កាន់តែធ្វើឲ្យគាត់ឃើញព្រះចេស្តារបស់ព្រះជាម្ចាស់ដែលព្រះអង្គបីបាច់ថែរក្សាដល់គ្រួសាររបស់គាត់យ៉ាងល្អ ។ លោកគ្រូតែងតែដឹកនាំកូនៗទាំងអស់ឲ្យមានជំនឿទុកចិត្តដល់ព្រះជាម្ចាស់ ដោយការដឹកនាំគ្រួសារពិចារណាបទគម្ពីរជារៀងរាល់យប់ ដោយលើកយកខគម្ពីរទំនុកតម្កើងជំពូក១ ជំពូក២៣ ជំពូក៩១ និងគម្ពីរម៉ាថាយជំពូក៥ជាដើម យកមក សិក្សា និងកំសាន្តចិត្តដល់កូនៗ ដើម្បីឲ្យកាន់តែទុកចិត្តដល់ព្រះជាម្ចាស់កាន់ តែខ្លាំងឡើងថែមទៀត ។ នៅកម្ពុជាក្រោមមិនសូវសម្បូណ៌ដើមត្នោត ដូចនៅកម្ពុជាភូមិភាគកណ្តាលយើងទេ ។ លោកគ្រូ ប្រកបរបរចិញ្ចឹមជីវិតជា កសិករផង និងធ្វើជាអ្នកឡើងត្នោតផង ។ លោកគ្រូ មានដើមត្នោតមួយដើមដែលចម្ងាយ២គីឡូម៉ែត្រពីកន្លែងដែលលោកគ្រូស្នាក់នៅ ។ ជីវភាពជាអ្នកធ្វើស្រែ និងឡើងត្នោត ដើម្បីផ្គត់ផ្គង់គ្រួសារផង

និងដើម្បីបំរើព្រះផងនោះ មិនមែនជាការងាយស្រួលឡើយ ។ តែព្រះជាម្ចាស់មានព្រះគុណលើសលប់ចំពោះគ្រួសាររបស់លោកគ្រូក្នុងរយៈពេល ៥ឆ្នាំ នៅឯកម្ពុជាក្រោម ។ ដោយសារព្រះគុណព្រះជាម្ចាស់ លោកគ្រូបានបង្កើតក្រុមជំនុំមួយកន្លែងនៅក្នុងខេត្ត ឃ្លាំង ។

លុះដល់ឆ្នាំ ១៩៧៩ ប្រទេសកម្ពុជាយើងត្រូវបានរំដោះឲ្យមានសេរីភាពពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ។ លោកគ្រូបានបញ្ចប់បេសកកម្មបំរើព្រះនៅកម្ពុជាក្រោម ។ លោកគ្រូបានធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ ។ នៅពេលដែលលោកគ្រូមកដល់ភ្លាម លោកគ្រូគង្វាល ៩០នាក់ ជំនាន់ជាមួយគ្នានឹងលោកគ្រូនោះ បានទៅនៅជាមួយនឹងព្រះជាម្ចាស់អស់ទៅហើយ គឺមាននៅសល់តែ៤នាក់គត់ ។ លោកគ្រូពីរនាក់សព្វថ្ងៃនៅសហរដ្ឋអាមេរិក និងគ្រូពីរនាក់ទៀតនៅក្នុងប្រទេសខ្មែរ គឺលោកគ្រូ ង៉ូវ វ៉ន និងលោកគ្រូ សៀង អង់ នេះឯង ។ ពេលនោះលោកគ្រូចាប់ផ្ដើមប្រមូលសិស្សដែលជាអ្នកជឿចាស់ៗខ្លះ និងផ្សាយដំណឹងល្អថ្មីខ្លះទៀត លោកគ្រូបង្កើតបានក្រុមជំនុំមួយដែលប្រៀបដូចជាផុសចេញពីគំនរផេះ ដែលភ្លើងសង្គ្រាមបានឆេះបន្សុះស្ទើរគ្មានសល់នោះ ។ ដោយយកគំរូតាមស្មារតីលោក នេហេមា លោកគ្រូបានខំធ្វើការបំរើព្រះយ៉ាងអស់អំពីចិត្ត មិនយូរប៉ុន្មាន ក្រុមជំនុំមួយបានកើតឡើងនៅក្នុងភូមិ ព្រែក តាឡុង សង្កាត់ចាក់អង្រែក្រោម ស្រុក មានជ័យ រាជធានីភ្នំពេញ ដោយបានដាក់ឈ្មោះថា "ព្រះវិហារតាខ្មៅ" ។

រហូតដល់ឆ្នាំ ១៩៨២ ក្រោយពីផ្សាយដំណឹងល្អ និងដើរសួរសុខទុក្ខក្រុមជំនុំដោយលួចលាក់ (ព្រោះកាលពីសម័យនោះ ក្រុមជំនុំមិនបានទទួលស្គាល់ជាផ្លូវការពីរដ្ឋាភិបាលនៅឡើយទេ) ។ លោកគ្រូបានធ្វើដំណើរទៅតាមតំបន់ជាយដែនខ្មែរ-ថៃ ដើម្បីស្វែងរកក្រុមជំនុំដែលនៅសល់ពីស្លាប់ក្នុងសម័យសង្គ្រាម ។ ពេលនោះគាត់បានទៅដល់ជំរំខៅអ៊ីដាងក្នុងទឹកដីថៃ ។ គាត់នៅបំរើព្រះទីនោះ ហើយគាត់បានជួបអ្នកបំរើព្រះចាស់ៗនៅទីនោះ ។ ក្រោយ

មកលោកគ្រូក៏មានឈ្មោះចេញទៅប្រទេសទីបី តែលោកគ្រូមិនព្រមទៅដោយ មិនចង់ចេញទៅតែម្នាក់ឯងចោលគ្រួសារនៅឯស្រុកខ្មែរផង ហើយដោយស្រឡាញ់ដល់ក្រុមជំនុំដែលកើតឡើងថ្មីផង លោកគ្រូក៏សម្រេចចិត្តវិលត្រឡប់មកភ្នំពេញវិញ នៅឆ្នាំ ១៩៨៤ ។ នៅពេលនោះការបៀតបៀនកាន់តែមានសភាពធ្ងន់ធ្ងរឡើងជាលំដាប់ តែការបៀតបៀននោះមិនអាចបញ្ឈប់លោកគ្រូពីការផ្សាយដំណឹងល្អ និងដើរសួរសុខទុក្ខក្រុមជំនុំឡើយ ។ នៅទីបំផុត រដ្ឋាភិបាលសម័យនោះគេបានឃាត់ខ្លួនគាត់ដោយដាក់គាត់ក្នុងទីឃុំឃាំង ដែលត្រូវជាប់នៅទីនោះពី ៣ ទៅ ៥ឆ្នាំ ។ នៅក្នុងទីឃុំឃាំង លោកគ្រូមានស្មារតីរឹងប៉ឹងតាមគំរូរបស់លោកប៉ូល ឥតមានខ្វល់ព្រួយអ្វីទាំងអស់ ទោះបីជាគេមិនអនុញ្ញាតឲ្យក្រុមជំនុំ និងកូនចៅចូលទៅសួរសុខទុក្ខគាត់ក៏ដោយ ក៏លោកគ្រូនៅតែបន្តនិយាយប្រាប់ពីដំណឹងល្អរបស់ព្រះយេស៊ូដល់អ្នកដែលជាប់ពន្ធនាគារជាមួយគ្នាឥតឈប់ ។ ដោយសារព្រះគុណព្រះ គាត់មិនបានជាប់នៅទីនោះយូរតាមពេលដែលគេកំណត់នោះឡើយ គឺអស់រយៈពេលតែ ១២០ថ្ងៃ ប៉ុណ្ណោះ គាត់ត្រូវទទួលសេរីភាពមកវិញ។

នៅឆ្នាំ ១៩៨៥ លោកព្រឹទ្ធាចារ្យ សៀង អង់ និងភរិយាបានបន្តបង្កើតក្រុមជំនុំរហូតដល់សព្វថ្ងៃ ដែលមានឈ្មោះថា "ព្រះវិហារតាអង់មេត្រីតាខ្មៅ" ។ ក្នុងការងារបំរើព្រះអស់រយៈពេល៤៨ឆ្នាំមកហើយ គ្មានប្រាក់ឧបត្ថម្ភ ឬជំនួយណាមួយពិតប្រាដកឡើយ តែព្រះជាម្ចាស់បានផ្គត់ផ្គង់បីបាច់ថែរក្សាលោកគ្រូព្រមទាំងភរិយារៀងរហូតមក ។ មកទល់ពេលនេះ លោកគ្រូមានជន្មាយុ ៨៤ឆ្នាំ និងភរិយាគាត់មានជន្មាយុ ៧៥ឆ្នាំ ។ លោកទាំងពីរមានកូនទាំងអស់ ៨នាក់ ប្រុស៣នាក់ និងស្រី៥នាក់ ។ នៅជំនាន់ប៉ុត ពត កូនប្រុស២នាក់បានស្លាប់ ហើយកូនស្រីម្នាក់បានស្លាប់នៅប្រទេសអូស្ត្រាលី ។ លោកព្រឹទ្ធាចារ្យ មានចៅ ២២នាក់ និងចៅទួត ៨នាក់ គេទាំងអស់សុទ្ធតែជាអ្នកជឿព្រះយេស៊ូទាំងអស់គ្នា ហើយកូនប្រសាប្រុស៣នាក់របស់គាត់ជាគ្រូគង្វាល ។

ឥឡូវនេះលោកព្រឹទ្ធាចារ្យបានចូលនិវត្តន៍ ហើយបានផ្ទេរការងារបំរើព្រះដល់កូនចៅជំនាន់ក្រោយ និងគណៈកម្មការចាស់ទុំក្នុងព្រះវិហារ ដើម្បីបំរើការងារបន្តពីលោកទាំងពីរ ។ នៅក្នុងបច្ឆិមវ័យរបស់គាត់ទាំងពីរ គឺជាពេលវេលាដ៏សែនសុខជុំមរមនា ដោយសារបានឃើញផលផ្លែនៃការងារបំរើព្រះដែលលោកបានបំពេញកន្លងមក និងបានឃើញកូនចៅច្រូងច្រាងល្អូតលាស់ ដោយជំនឿប្រៀបបីដូចជាលំពង់អូលីវលាស់ខៀវខ្ចី នេះជាពរជ័យដែលព្រះជាម្ចាស់បានប្រទានជូនលោកទាំងពីរ ។ នេះជាគំរូមួយដ៏ប្រសើរសំរាប់យើងរាល់គ្នា នៅពេលដែលយើងទុកចិត្តទាំងស្រុងលើការផ្គត់ផ្គង់របស់ព្រះជាម្ចាស់ នោះយើងនឹងមិនខកចិត្តដូចយើងដាក់ការទុកចិត្តរបស់យើងទៅលើមនុស្សណាម្នាក់នោះទេ ។ បើសិនជាលោកគ្រូទុកចិត្តលើមនុស្សតាមដែលពាក្យគេសន្យាកាលពីពេលដែលគាត់ទៅជាបេសកជននៅកម្ពុជាក្រោម ប្រហែលជាគាត់មិនអាចបំរើព្រះបានទេ ។ តែអរព្រះគុណព្រះជាម្ចាស់ដែលលោកទាំងពីរបានទុកចិត្តលើព្រះជាម្ចាស់ជាជាងលើមនុស្ស ទើបការងារបំរើព្រះរបស់លោកទាំងពីរបានទទួលនូវជោគជ័យ អាចឲ្យយើងយកធ្វើជាគំរូបាន។ អាម៉ែន ។



HONEYCOMB 4/2 (July 2003): 73–76



*UON Seila*

# Meet Pastor Seang Aung



*SEANG Aung*

Pastor Seang Aung was born on May 19, 1918. He was raised in a Buddhist farmer's family in Roeusey village, Baray subdistrict, Trang district, Takeo province. His parents are Mr. Seang Beth and Mrs. Am. Pastor Seang Aung has four sisters, and is himself the fourth child in the family.

In 1934 he entered the monkhood, where he remained for eight years. Praise God for giving him this opportunity to learn first hand about the Buddhist faith, because this knowledge would later help him in his evangelistic work. In 1943 he married Bun Sok, who lived in the

same village. He was converted to Christ by a Christian and Missionary Alliance pastor, Chum Beang, and then attended the Bible School in Takhau town, Kandal province, for four years. After graduating he worked as an evangelist with the Christian and Missionary Alliance.

In 1954 Pastor Seang Aung went to evangelize in Takeo province. As a result, many people converted to Christ. The authorities accused him of disgracing Buddhism and inciting people to betray their own religion, and arrested him. He was asked to pay 2,500 riel. In those days that was a high sum, but they said if he did not pay they would not release him. His wife borrowed money from relatives and paid the authorities as the deadline required. But thank God for working miracles in their lives. The authorities seemed frightened, returned the money, and apologized to him.

In 1961 he went to serve the Lord in Prek Kranh village, Psar SreThom KomChay mountain, Toek Laok subdistrict, Prey Nop district, Kampot province. He planted a church there for the Lord, and stayed in Kampot until 1970.

A Christian conference in Phnom Penh decided to send volunteers to work as missionaries in Kampuchea Kraom. He volunteered to serve in Klang province, Kampuchea Kraom. Before he left, the central committee pledged to support him every month. But when he reached this new place that was not his home country he encountered a lot of persecution, and the promised support did not come. His family faced severe hardship. He stayed in MonoTen village, Prek Roeusy subdistrict, Klang province, Kampuchea Kraom. Because of his experience in Buddhism he could share the Good News with the Buddhist monks and people in Kampuchea Kraom very easily, but at the same there was also a lot of persecution.

When he was in Kampuchea Kraom he received no salary from Cambodia, and so entrusted himself to God's provision. God proved to be so faithful in caring for his family. He always encouraged his children to trust God, and he led a Bible study for his family every night before bedtime. He quoted verses from Psalms 1, 23, and 91, and from Matthew 5, to remind his children to put their trust in the Lord. Kampuchea Kraum does not have many palm trees, as does most of Cambodia. He earned his living by farming and climbing palm trees to

collect juice to sell. There was one palm tree about two kilometers from his place. His life of farmer and palm tree climber was not easy, but God provided what he needed and took care of his family during their five years in Kampuchea Kraom. By the grace of God he was able to plant a church in Klang province.

In 1979 Cambodia was delivered from the hand of the Khmer Rouge and the genocidal Pol Pot régime. His mission as missionary in Kampuchea Kraum thus ended, he repatriated to Cambodia. Upon arrival he learned that forty pastors who had graduated from Takhau Bible School had been promoted into glory with God. Only four pastors remained alive. Two are living in the United States, and two in Cambodia—Ngov Vorn and Seang Aung. At that time he started to gather some remnants and new converts, and established one church out of the scratch the war had left us. In the spirit of Nehemiah he worked very hard for the Lord, and before long one church emerged in Prek Talong village, Sangkat Chak Aungre Kraum, Meanchey district, Phnom Penh. He named it "Ta Khau Church."

In 1982 he went to share the gospel and visit some congregations in secret, because in those days the government did not recognize Christianity. Then he traveled to the Thai border area to visit some war remnant Christians. He settled in Kao I Dang camp, Thailand, to serve the Lord, and there met some of his old friends. Eventually he was chosen to resettle in a third country, but refused to go for two reasons: he did not want to go alone, and he did want to leave the church in the midst of troubles. Rather, he decided to return to Phnom Penh in 1984. There he faced tension and more persecutions every day, but they could not stop him from sharing the gospel and visiting churches. At last he was arrested, sentenced to three to five years, and thrown into jail. In prison he did as Paul and refused to worry, even though they banned church members and relatives from visiting him. In jail he still kept telling people about Jesus. By the grace of God he remained in jail only one hundred twenty days.

In 1985 pastor Seang Aung and his wife continued to serve God, and planted a church that today is called "Ta Aung Metrey Takhau Church." In forty-eight years of serving the Lord he never enjoyed regular financial support from any group, but God took care of him and

his family. He is now eighty-four years and his wife seventy-five. They have three sons and five daughters. Two sons died in the Pol Pot régime, and one daughter died in Australia. They have twenty-two grandchildren and four great grandchildren. They all are Christian, and three of his son's-in-law are pastors.

Pastor Seang Aung is retiring as pastor and has given all the responsibilities to his children and the board of elders in the church. He and his wife live with happiness in their old age as they see the fruit of their effort over the past years, and their children and grandchildren maturing in their faith like the sprout of the olive. This is the blessing by which God has honored their hard work and their trust in Him rather than in people. Had he put his trust in people and their pledges while he was in Kampuchea Kraom, he might not have ended up serving God until his old age. Praise God that they both put their trust in the Lord rather than in man. Therefore they have been successful in serving the Lord, and provide us a good example. Amen.

